# ជំនួយសុខភាពផ្លូវចិត្ត

# ភាគ ២




រៀបរៀងដោយ

សាមណេរ

ធម្មាលង្ការោ ចាន់ សុជន

សព្វទានំ ធម្មទានំ ជិនាតិ

# នមស្សការព្រះត្រៃរតន៍

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

សូមនមស្ការ ចំពោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ) ដោយសេចក្ដីគោរព ។

ខ្ញុំព្រះអង្គម្ចាស់ សូមក្រាបថ្វាយបង្គំ ចំពោះព្រះសម្មាសម្ពុទ្ធ ដែលព្រះសម្មាសម្ពុទ្ធអង្គនោះ ប្រៀបដូចជារស្មីនៃព្រះច័ន្ទពេញបូរមី ។

ខ្ញុំព្រះអង្គម្ចាស់ សូមក្រាបថ្វាយបង្គំចំពោះព្រះសទ្ធម្ម ដែល ព្រះសទ្ធម្មនោះ ប្រៀបដូចជារស្មីនៃព្រះច័ន្ទ ។

ខ្ញុំព្រះអង្គម្ចាស់ សូមក្រាបថ្វាយបង្គំចំពោះព្រះសង្ឃ ដែលព្រះសង្ឃនោះ ប្រៀបដូចជាលោកនេះ ដែលស្រស់បស់ដោយរស្មី នៃព្រះច័ន្ទពេញបូរមីនោះ ។

ដោយសេចក្ដីជ្រះថ្លា ចំពោះព្រះគុណព្រះរតនត្រ័យ ខ្ញុំព្រះករុណាសូមតាំងចិត្តថា ដរាបណាខ្ញុំព្រះករុណាមិនទាន់បានត្រាស់ដឹងនូវសច្ចធម៌ សូមឲ្យបានជួបព្រះរតនត្រ័យ ជួបសប្បុរស ជាប់នូវសីលគ្រប់ៗជាតិ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹង ទីរលឹក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ ជាទីពឹង ទីរលឹក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរលឹក ស្មើដោយត្បូងរបស់ខ្ញុំព្រះករុណា ។

# អារម្ភកថា

សៀវភៅជំនួយសុខភាពផ្លូវចិត្តភាគ១ អាត្មាភាពបាន រៀបចំចងក្រងជាសៀវភៅរួចទៅហើយ ។ ឥឡូវនេះ ខ្ញុំព្រះករុណា អាត្មាភាព បានសរសេរសៀវភៅមួយក្បាលទៀត មានឈ្មោះថា **ជំនួយសុខភាពផ្លូវចិត្តភាគ ២** ។

សូមបញ្ជាក់ថា ហេតុដែលខ្ញុំព្រះករុណា អាត្មាភាពឲ្យ ឈ្មោះសៀវភៅយ៉ាងនេះ ព្រោះបាននឹកឃើញដល់ព្រះពុទ្ធដីកា ដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់សម្តែងថា ៖

ម្នាលភិក្ខុទាំងឡាយ ជម្ងឺមានពីរយ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ជម្ងឺ ២ យ៉ាង តើដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ ជម្ងឺ ២ យ៉ាងគឺ ជម្ងឺផ្លូវកាយ ១ ជម្ងឺផ្លូវចិត្ត ១ ។ រួចព្រះអង្គសម្តែងបន្តទៀតថា ជម្ងឺផ្លូវកាយស្រួលព្យាបាលជាងជម្ងឺផ្លូវចិត្ត, ជម្ងឺផ្លូវចិត្តមិនងាយព្យាបាលឡើយ ។ ព្រោះហេតុដូច្នេះ បានជាខ្ញុំព្រះករុណា អាត្មាភាព ដាក់ឈ្មោះសៀវភៅថា **ជំនួយសុខភាពផ្លូវចិត្ត** ។

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព សរសេរដោយ មានគោលបំណងយ៉ាងនេះគឺ

-ជាប្រយោជន៍ដល់ពុទ្ធបរិស័ទ អ្នកសិក្សាព្រះអភិធម្ម

-ជាជំនួយដល់ផ្លូវចិត្ត ព្រោះថាចិត្តកំពុងតែមានជម្ងឺ

-ដើម្បីឲ្យព្រះពុទ្ធសាសនាមានព្រះធម៌ ព្រះវិន័យស្ថិតនៅយូរអង្វែង សម្រាប់ភិក្ខុ សាមណេរ ឧបាសក ឧបាសិកា គោរពប្រតិបត្តិដោយបដិបត្តិបូជា ធ្វើនៅទីបំផុតនៃសេចក្តីទុក្ខបាន ។

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព មិនហ៊ានអះអាងថាល្អឥតខ្ចោះនោះទេ ព្រោះហេតុដូច្នេះ កំហុសខុសឆ្គងណាដែលកើតឡើងដោយអចេតនាណានីមួយ សូមអ្នកចេះដឹងទាំងឡាយ មេត្តាកែសម្រួលដោយអនុគ្រោះផងចុះ ។

**នត្ថិ សន្តិ បរំ សុខំ**

*ពុំមានសេចក្តីសុខដទៃក្រៅអំពីសេចក្តីស្ងប់ឡើយ ។*

វេឡុវ័ន,១៥ កើត ខែមាឃ ព.ស ២៥៤៩

# ឧទ្ទិសកថា

ខ្ញុំព្រះករុណា អាត្មាភាព សូមគោរពដឹងគុណចំពោះ អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតា គ្រូឧបជ្ឈាយាចារ្យ ជាដើម ។

ម្យ៉ាងវិញទៀត ខ្ញុំព្រះករុណា សូមឧទ្ទិសនូវបុណ្យកុសលក្នុងការចងក្រងសៀវភៅជំនួយសុខភាពផ្លូវចិត្តភាគ ២ នេះ ជូនចំពោះលោកអ្នកមានគុណទាំងពីរ និងសូមប្រគេនបុណ្យចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ គ្រប់ជំនាន់ទាំងអស់ សូមប្រគេនបុណ្យ ចំពោះព្រះសង្ឃទាំងអស់គ្រប់ជំនាន់ និងសូមថ្វាយនូវព្រះរាជកុសល ចំពោះព្រះមហាក្សត្រគ្រប់ជំនាន់ទាំងអស់ ជាពិសេស ថ្វាយព្រះរាជកុសល ដល់ព្រះមហាក្សត្រថ្មី ព្រះនាមនរោត្តម សីហមុនី ជាទីគោរពសក្ការៈ និងជាម្លប់របស់កូនចៅទាំងអស់គ្នា ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំព្រះករុណា សូមគោរពដឹងគុណចំពោះ ព្រះគ្រូ និងលោកគ្រូរបស់ខ្ញុំទាំងឡាយ និងសូមប្រគេនបុណ្យ និងជូនបុណ្យចំពោះ អ្នកមានគុណទាំងឡាយនោះ ដូចមានរាយនាមខាងក្រោមនេះ ៖

១-លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស

២-ព្រះគ្រូធម្មាចារ្យ សោភណត្ថេរោ សោម សុភាព

៣-លោកគ្រូធម្មាចារ្យ រស់ សុផាត

៤-លោកឪពុក ចាន់ សាមឿន

៥-អ្នកម្តាយ ឃួន សាខន និងអ្នកមានគុណដទៃទៀត ដែលមិនអាចរៀបរាប់ឈ្មោះអស់ ។ សូមកុសល ដែលខ្ញុំបានកសាងហើយ ជួយឧបត្ថម្ភគាំទ្រ ចំពោះជីវិតដែលអន្ទោល ទៅក្នុងសង្សារវដ្ត សូមឲ្យមានឧបនិស្ស័យជួបព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃគ្រប់ជាតិ ជួបសប្បុរសគ្រប់ជាតិ ស្តាប់ធម៌សប្បុរស គ្រប់ជាតិ មានសទ្ធាគ្រប់ជាតិ ជាប់នូវសីលគ្រប់ជាតិ ទីបំផុតជាតិ សូមឲ្យបានត្រាស់ដឹងនូវសច្ចធម៌ គ្រប់ព្រះអង្គ គ្រប់គ្នា ។

*សូមអនុមោទនា !!!*

# សារប័ណ្ណ

ឈ្មោះអត្ថបទ ទំព័រ

-នមស្សការព្រះត្រៃរតន៍............................... ក

-អារម្ភកថា................................................... គ

-ឧទ្ទិសកថា................................................... ង

**អហេតុកចិត្ត ១៨ ដួង**

-ពាក្យថា អហេតុកចិត្ត.................................... ១

-ពាក្យថាអកុសលវិបាកចិត្ត............................. ២

**អកុសលវិបាកចិត្ត៧ដួងគឺ**

-អកុសលវិបាកចិត្តដួងទី១.............................. ៣

-ធម៌អប់រំចិត្ត ស្តីអំពីកាយជារបស់មិនស្អាត... ៤

-អកុសលវិបាកចិត្តដួងទី២.............................. ៥

-ធម៌អប់រំចិត្ត ស្តីអំពីបួសយូរ តែមិនស្គាល់

សេចក្តីស្ងប់ ..................................................... ៦

-អកុសលវិបាកចិត្តដួងទី៣.............................. ៧

-ធម៌អប់រំចិត្ត ស្តីអំពីមិនមានសេចក្តីស្ងប់ចិត្ត.... ៨

-អកុសលវិបាកចិត្តដួងទី៤................................ ៩

-ធម៌អប់រំចិត្ត ស្តីអំពី សេចក្តីសោកគ្របសង្កត់ចិត្ត.១០
-អកុសលវិបាកចិត្តដួងទី៥.............................. ១១
-ធម៌អប់រំចិត្ត ស្តីអំពី កាម ឧបមាដូចលំពែង...... ១២
-អកុសលវិបាកចិត្តដួងទី៦.............................. ១៣
-ធម៌អប់រំចិត្ត ស្តីអំពីការតំកល់ចិត្តមាំល្អ........... ១៤
-អកុសលវិបាកចិត្តដួងទី៧.............................. ១៥
-ធម៌អប់រំចិត្ត ស្តីអំពីដឹងខ្លួន,កែខ្លួន,ខ្លួនល្អ......... ១៦
-តារាងអកុសលវិបាកចិត្ត៧ដួង........................ ១៧
-ពាក្យថា អហេតុកកុសលវិបាកចិត្ត................. ១៧

## អហេតុកកុសលវិបាកចិត្ត៨ដួង

-អហេតុកកុសលវិបាកចិត្តទី១.......................... ១៩
-ធម៌អប់រំចិត្ត ស្តីអំពីភ្លើងកិលេស.................... ២០
-អហេតុកកុសលវិបាកចិត្តដួងទី២................... ២១
-ធម៌អប់រំចិត្ត ស្តីអំពីជាងផ្ទះគឺតណ្ហា.............. ២២
-អហេតុកកុសលវិបាកចិត្តដួងទី៣.................. ២៣
-ធម៌អប់រំចិត្ត ស្តីអំពី មិនដឹងធម៌ពិត................ ២៤
-អហេតុកកុសលវិបាកចិត្តដួងទី ៤................. ២៥
-ធម៌អប់រំចិត្ត ស្តីអំពីនៅម្នាក់ឯងមិនមានភ័យ... ២៦

-អហេតុកកុសលវិបាកចិត្តដួងទី ៥.................. ២៧
-ធម៌អប់រំចិត្តស្តីអំពីដឹងនូវធម៌ពិត.................... ២៨
-អហេតុកកុសលវិបាកចិត្តដួងទី៦.................... ២៩
-ធម៌អប់រំចិត្ត ស្តីអំពីរូបអាក្រក់តែចិត្តល្អ........... ៣០
-អហេតុកកុសលវិបាកចិត្តដួងទី៧................... ៣១
-ធម៌អប់រំចិត្ត ស្តីអំពី ធ្វើយ៉ាងណា និយាយ
យ៉ាងនោះ...................................................... ៣២
-អហេតុកកុសលវិបាកចិត្តដួងទី៨.................. ៣៣
-ធម៌អប់រំចិត្ត ស្តីអំពី ស្រឡាញ់ភាពជាសាមណៈ ៣៤
-តារាងអហេតុកអកុសលវិបាកចិត្ត ៨ ដួង ៣៤

## ពាក្យថាអហេតុកកិរិយាចិត្ត

-អហេតុកកិរិយាចិត្តដួងទី១............................. ៣៦
-បញ្ចទ្វារាវជ្ជនចិត្ត .......................................... ៣៧
-លក្ខណាទិចតុករបស់បញ្ចទ្វារាវជ្ជនៈ ............ ៣៨
-ធម៌អប់រំចិត្ត ស្តីអំពី សុខចិត្តចង់ក ព្រោះមិន
ចង់សឹក.......................................................... ៣៨
-អហេតុកកិរិយាចិត្តដួងទី២ ......................... ៤០
-មនោទ្វារាវជ្ជនចិត្ត......................................... ៤១

-ធម៌អប់រំចិត្ត ស្តីអំពី ទោសរបស់កាម............. ៤២
-អហេតុកកិរិយាចិត្តដួងទី ៣ ....................... ៤៤
-ហសិតុប្បាទចិត្ត ........................................ ៤៥
-លក្ខណាទិចតុករបស់ហសិតុប្បាទចិត្ត ......... ៤៧
-ធម៌អប់រំចិត្ត ស្តីអំ ពីពាក្យពិតមិនប្រែប្រួល.... ៤៨

## ឧប្បត្តិហេតុនៃអហេតុកចិត្ត

-ហេតុឲ្យកើតចក្ខុវិញ្ញាណ ២ ដួង មាន ៤........ ៥៣
-ធម៌អប់រំចិត្ត ស្តីអំពី ការធ្វើចិត្តឱ្យត្រង់........... ៥៤
-លក្ខណាទិចតុករបស់ចក្ខុវិញ្ញាណ................ ៥៥
-អធ៌អប់រំចិត្តស្តីអំពី ចិត្តជាធម្មជាតិស្រាល....... ៥៥
-ហេតុនាំឲ្យកើតសោតវិញ្ញាណ ២ ដួង មាន ៤. ៥៦
-ធម៌អប់រំចិត្ត ស្តីអំពី ចិត្តជាធម្មជាតិល្អិត......... ៥៦
-លក្ខណាទិចតុករបស់សោវិញ្ញាណ .............. ៥៧
-ធម៌អប់រំចិត្ត ស្តីពី ត្រាច់ទៅតែឯង................. ៥៧
-ហេតុឱ្យកើតឃានវិញ្ញាណ ២ដួង មាន៤ ...... ៥៨
-ធម៌អប់រំចិត្តស្តីអំពីចិត្តមិនទទឹកដោយកិលេស ៥៨
-លក្ខណាទិចតុករបស់ឃានវិញ្ញាណ ............. ៥៩
-ធម៌អប់រំចិត្តស្តីអំពីកាយឧបមាដូចផ្ទាំងដី ....... ៦០

-ហេតុឱ្យកើតជីវ្ហាវិញ្ញាណ ២ ដួង មាន៤ ......... ៦០
-ធម៌អប់រំចិត្ត ស្ដីអំពី កាយដូចអង្កត់ឱស......... ៦១
-លក្ខណាទិចតុក្កុរបស់ជីវ្ហាវិញ្ញាណ ................ ៦២
-ធម៌អប់រំចិត្ត ស្ដីអំពី ការតម្កល់ចិត្តខុស........... ៦២
-ហេតុឱ្យកើតកាយវិញ្ញាណ ២ ដួង មាន៤ ...... ៦៣
-ធម៌អប់រំចិត្តស្ដីអំពី ការតំកល់ចិត្តត្រូវ ............ ៦៣
-លក្ខណាទិចតុក្ករបស់កាយវិញ្ញាណ ............. ៦៤
-ធម៌អប់រំចិត្តស្ដីអំពី កូន៣យ៉ាង...................... ៦៤
-ហេតុឱ្យកើតមនោធាតុ ៣ មាន ៤ .............. ៦៧
-ធម៌អប់រំចិត្ត ស្ដីអំពី អកុសលវិតក្កៈ ៣ យ៉ាង.. ៦៨
-លក្ខណាទិចតុក្ករបស់មនោធាតុ..................... ៦៩
-ធម៌អប់រំចិត្តស្ដីអំពី កូន ៣ យ៉ាង ................... ៧០
-ហេតុឱ្យកើតមនោវិញ្ញាណធាតុ ៧៦ មាន៤.. ៧២
-ហេតុឲ្យកើតមនោវិញ្ញាណធាតុ ម្យ៉ាងទៀត.... ៧២
-ធម៌អប់រំចិត្ត ស្ដីអំពី ការសង្រ្គួម...................... ៧៤
-លក្ខណាទិចតុក្ករបស់មនោវិញ្ញាណធាតុ ...... ៧៥
-ធម៌អប់រំចិត្ត ស្ដីអំពី ការជំរុះកិលេស............. ៧៥
-អហេតុកកថាបន្ថែម....................................... ៧៦
-គាថាសង្គហៈ .................................................. ៨០

## វេទនានុបស្សនាសតិប្បដ្ឋាន

-ពាក្យថាវេទនា................................................ ៨១
-លក្ខណាទិចតុករបស់វេទនា.......................... ៨២
-លក្ខណាទិចតុករបស់សុខវេទនា................... ៨២
-លក្ខណាទិចតុករបស់ទុក្ខវេទនា ................... ៨៣
-លក្ខណាទិចតុករបស់សោមនស្សវេទនា........ ៨៣
-លក្ខណាទិចតុករបស់ទោមនស្សវេទនា......... ៨៣
-លក្ខណាទិចតុករសប់ឧបេក្ខាវេទនា.............. ៨៤
-សេចក្ដីពន្យល់បន្ថែមអំពីវេទនា..................... ៨៥
-អានិសង្សរបស់វេទនា ................................. ៩០
-កាលរលាស់ចោលនូវវេទនា.......................... ៩០
-គ្រែកអរនឹងវេទនាឈ្មោះគ្រែកអរនឹងទុក្ខ........ ៩១
-វិញ្ញាណរលត់ព្រោះអត់គ្រែកអរនឹងវេទនា...... ៩១
-ផ្លូវមូលតែមួយមិនមានពីរ ............................ ៩១

## នាទីកំណាព្យ

-ឧបមាព្រះរតនត្រ័យ ២២ ប្រការ.................... ៩៣
-ចាញ់បោកខន្ធ៥ ............................................ ១០០

# អហេតុកចិត្ត ១៨ ដួង
# ពាក្យថា អហេតុកចិត្ត

**អហេតុកចិត្ត** មកពី (ន + ហេតុ + ក + ចិត្ត ) ប្រែថា ចិត្តមានហេតុមិនមាន ។ អហេតុក មានវិគ្គហៈ ថា **នត្ថិ ហេតុ អស្សាតិ** > **អហេតុកោ** ។ ដូច្នេះពាក្យថា អហេតុកចិត្ត ជាចិត្តដែលមិនមានហេតុ ៦ ប្រកប ឬ ចិត្តដែលមិនប្រកបដោយហេតុ៦ ។ ពាក្យថា **ហេតុ** មកពី ( ហិ + តុ ) បុំលិង្គ ( សភាវៈ ) ជាទីតាំងនៃផល ឬ ជាទីប្រព្រឹត្តទៅនៃផល ឈ្មោះថា **ហេតុ** មានវិគ្គហៈថា **ហិនោតិ បតិដ្ឋា ផលមេត្ថាតិ ហិនោតិ បវត្តតិ ផលមេត្ថាតិ វា** > **ហេតុ** ។

ដូច្នេះចំពោះហេតុ ដែលប្រែសេចក្តីមកថា ជាទីតាំងនៃផល នោះមាន ៦ ប្រការគឺ លោភហេតុ ១ ទោសហេតុ ១ មោហហេតុ ១ អលោភហេតុ ១ អទោសហេតុ ១ អមោហហេតុ ១ ហេតុទាំង ៦ នេះ មិនប្រកបជាមួយចិត្តណា ចិត្តនោះឈ្មោះថា អហេតុកចិត្ត ។ ហើយអហេតុកចិត្តនេះ លោកបែងចែកជា ៣ ប្រការ គឺ អកុសលវិបាកចិត្ត ១ អហេតុកកុសលវិបាកចិត្ត ១ អហេតុកកិរិយាចិត្ត ១ សរុបទាំង៣ប្រការ ហៅថា អហេតុកចិត្ត មានចំនួន ១៨ ដួង ។

# ពាក្យថាអកុសលវិបាកចិត្ត

**អកុសលវិបាកចិត្ត** មកពី ( អកុសល + វិបាក + ចិត្ត ) ឬ អកុសលមកពី ( ន + កុសល ) អកុសល បានសេចក្ដីថា មិនមែនជាកុសល ឬ មិនប្រសប់ មិនឈ្លាស មិនវាងវៃ ។

**វិបាក** មកពី ( វិ + បច + ណ, ប > បា ច > ក ) ប្រែមកថា ឆ្អិនដោយពិសេស ឬ ផលដ៏ឆ្អិន។ មានវិគ្គហៈថា **វិនច្ចនំ វិបាកោ** ។ **អកុសលវិបាកចិត្ត** ប្រែថា ចិត្តដែលជាផលរបស់អកុសលកម្ម ដែលបានសន្សំធ្វើទុកហើយពីកាលមុន ។

<u>ពាក្យគួរគិត</u>

ជីវិតកើតមកដើម្បីអ្វី ?

<u>ពាក្យកំសត់</u>

**កិច្ឆោ មនុស្ស បដិលាភោ**
ការបានកើតជាមនុស្ស ជាការក្រ
**កិច្ឆំ មច្ចាន ជីវិតំ**
ជីវិត គឺជាការរស់នៅ បានដោយក្រ
**កិច្ឆំ សទ្ធម្មស្សវនំ**
ការបានស្ដាប់ធម៌ ជាការក្រ
**កិច្ឆោ ពុទ្ធានមុប្បាទោ**
ការត្រាស់ដឹងឡើងនៃព្រះពុទ្ធជាការក្រ ។

## អកុសលវិបាកចិត្ត ៧ ដួង ៗ

## អកុសលវិបាកចិត្តដួងទី១

**១-ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ អកុសលវិបាកចិត្តំ**

*ចក្ខុវិញ្ញាណ ដែលជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា មានការឃើញនូវរូបមិនល្អ។*

**មានចេតសិកប្រកប៧គឺ**

*សព្វចិត្តសាធារណចេតសិក៧*

**ចែកជាខន្ធ**

*-វេទនាចេតសិក ជាវេទនាខន្ធ*

*-សញ្ញាចេតសិក ជាសញ្ញាខន្ធ*

*-ចេតសិក៥ ជាសង្ខារក្ខន្ធ*

*-ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ*

**ចែកជាធាតុ**

*-ចេតសិក៧ ជាធម្មធាតុ*

*-ចិត្តដួងនេះ ជាចក្ខុវិញ្ញាណធាតុ*

**ចែកជាអាយតន**

*-ចេតសិក៧ ជាធម្មាយតន*

*-ចិត្តដួងនេះ ជាមនាយតន*

**ចែកជាសច្ច**

*-ចេតសិក៧ ជាទុក្ខសច្ច*

*-ចិត្តដួងនេះ ជាទុក្ខសច្ច ។*

# ធម៌អប់រំចិត្ត

បិ.៥៧.ទំ.១៩៩.នន្ទាថេរី ស្ដីអំពីកាយជារបស់មិនស្អាត

*ម្នាលនន្ទា នាងចូរមើល (រាងកាយនេះ) មានជម្ងឺជានិច្ច មិនស្អាត ជារបស់ស្អុយ ដែលឆ្អឹង ៣០០ កំណាត់ផ្គុំឡើង ហើយចូរនាងអប់រំ*

*ចិត្តដោយអសុភសញ្ញា ឱ្យជាចិត្តមានអារម្មណ៍តែមួយ តាំងនៅមាំល្អ ។ ចូរនាងចម្រើននូវអនិមិត្ត ចូរលះបោលនូវមានានុស័យ នាងនឹងបានស្ងប់រម្ងាប់ ព្រោះបានលះនូវមានៈនោះ ។ ឮថាព្រះមានព្រះភាគទ្រង់ទូន្មានរឿយៗ នូវសិក្ខមានាឈ្មោះ នន្ទា ដោយគាថាទាំងនេះ ដោយប្រការដូច្នេះ។*

*<u>ពាក្យគួរយល់ដឹង</u>*

**ជីវិតកើតមកដើម្បីរស់**

*<u>ពាក្យកំសត់</u>*

**ពេលណាឃ្នុំ ! បានអាត្មារអញរួចចាកវដ្ដសង្សារ**

## អកុសលវិបាកចិត្តដួងទី២

**២-ឧបេក្ខាសហគតំ សោតវិញ្ញាណំ អកុសលវិបាកចិត្តំ** *សោតវិញ្ញាណ ដែលជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយគ្នានឹងឧបេក្ខាវេទនា មានការឮនូវសំឡេងមិនល្អ ។*

**មានចេតសិកប្រកប៧គឺ**

*សព្វចិត្តសាធារណចេតសិក៧*

**ចែកជាខន្ធ**

*-វេទនាចេតសិក ជាវេទនាខន្ធ*

*-សញ្ញាចេតសិក ជាសញ្ញាខន្ធ*

*-ចេតសិក៥ ជាសង្ខារក្ខន្ធ*

*-ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ*

**ចែកជាធាតុ**

*-ចេតសិក៧ ជាធម្មធាតុ*

*-ចិត្តដួងនេះ ជាសោតវិញ្ញាណធាតុ*

**ចែកជាអាយតន**

*-ចេតសិក៧ ជាធម្មាយតន*

*-ចិត្តដួងនេះ ជាមនាយតន*

**ចែកជាសច្ច**

*-ចេតសិក៧ ជាទុក្ខសច្ច*

*-ចិត្តដួងនេះ ជាទុក្ខសច្ច ។*

# ធម៌អប់រំចិត្ត

បិ.៥៧.ទំ.១៥៣.សាមាថេរី ស្តីអំពីបួសយូរ តែមិនស្គាល់សេចក្តីស្ងប់

*តាំងពីអាត្មាអញបួសមកបាន ២៥ ឆ្នាំហើយ អាត្មាអញ មិនទាន់បានស្គាល់នូវសេចក្តីស្ងប់ចិត្តម្តងទេ ។ អាត្មាអញ មិនបានសេចក្តីស្ងប់ចិត្ត មិនលុះអំណាចក្នុងការនោចិត្ត តែតមកអាត្មាអញ ឮកដល់សាសនានៃព្រះជិនស្រី ក៏បានដល់នូវសេចក្តីសង្វេគ ។ អាត្មាអញត្រូវទុក្ខព្រះធម៌ ជាច្រើនពាល់ត្រូវហើយ ជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ បានសម្រេចនូវការអស់ទៅនៃតណ្ហា សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ថ្ងៃនេះ ជារាត្រីទី ៧ របស់អាត្មាអញ ជារាត្រីដែលតណ្ហារីងស្ងួត ។*

*<u>ពាក្យគួរគិត</u>*

**ជីវិតរស់នៅដើម្បីអ្វី?**

*<u>ពាក្យកំសត់</u>*

**តើអាត្មាអញ**

**ដឹងថាខ្លួនកំពុងមានទុក្ខដែរឬទេ?**

## អកុសលវិបាកចិត្តដួងទី៣

**៣-ឧបេក្ខាសហគតំ ឃានវិញ្ញាណំ អកុសលវិបាកចិត្តំ**

*ឃានវិញ្ញាណដែលជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយគ្នានិងឧបេក្ខាវេទនា មានការដឹងក្លិនមិនល្អ ។*

**មានចេតសិកប្រកប៧ គឺ**

*សព្វចិត្តសាធារណចេតសិក៧*

**ចែកជាខន្ធ**

*-វេទនាចេតសិក ជាវេទនាខន្ធ*

*-សញ្ញាចេតសិក ជាសញ្ញាខន្ធ*

*-ចេតសិក៥ ជាសង្ខារក្ខន្ធ*

*-ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ*

**ចែកជាធាតុ**

*-ចេតសិក៧ ជាធម្មធាតុ*

*-ចិត្តដួងនេះ ជាឃានវិញ្ញាណធាតុ*

**ចែកជាអាយតន**

*-ចេតសិក៧ ជាធម្មាយតន*

*-ចិត្តដួងនេះ ជាមនាយតន*

**ចែកជាសច្ច**

*-ចេតសិក៧ ជាទុក្ខសច្ច*

*-ចិត្តដួងនេះ ជាទុក្ខសច្ច ។*

# ធម៌អប់រំចិត្ត

*បិ.៥៧.ទំ.១៥៣. ឧត្តមាថេរី ស្ដីអំពីមិនមានសេចក្ដីស្ងប់ចិត្ត អាត្មាអញមិនបានសេចក្ដីស្ងប់រម្ងាប់ចិត្ត មិនលុះក្នុងអំណាចភាវនាចិត្ត បានចេញទៅខាងក្រៅ អំពីលំនៅ ៤ ដង ៥ ដង ។ អាត្មាអញបានចូលទៅរកភិក្ខុនី ដែលអាត្មាអញគួរជឿ(បដាចារាថេរី) ភិក្ខុនីនោះបានសម្ដែងធម៌គឺ ខន្ធ ធាតុ អាយតនៈ ដល់អាត្មាអញ ។ លុះអាត្មាអញ បានស្ដាប់ធម៌របស់លោក ក៏ឆ្អែតដោយ បីតិ និង សុខៈ អង្គុយលើបល្ល័ង្កមួយអស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី៨ អាត្មាអញបានទំលាយគំនរងងឹត គឺមោហៈ ហើយសណ្ដូកជើងទាំងគូ ។*

*ពាក្យគួរដឹង*

**ជីវិតរស់នៅដើម្បីធ្វើល្អ**

*ពាក្យកំសត់*

**➪...ក្នុងលោកនេះ គ្រប់អ្វីៗ មិនស្មើគ្រាប់បុណ្យឡើយ**

# អកុសលវិបាកចិត្តដួងទី៤

## ៤-ឧបេក្ខាសហគតំ ជីវ្ហាវិញ្ញាណំ អកុសលវិបាកចិត្តំ

*ជីវ្ហាវិញ្ញាណ ដែលជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយគ្នានឹងឧបេក្ខាវេទនា មានការដឹងនូវរសមិនល្អ ។*

**មានចេតសិកប្រកប៧គឺ**

*សព្វចិត្តសាធារណចេតសិក៧*

**ចែកជាខន្ធ**

*-វេទនាចេតសិក ជាវេទនាខន្ធ*

*-សញ្ញាចេតសិក ជាសញ្ញាខន្ធ*

*-ចេតសិក៥ ជាសង្ខារក្ខន្ធ*

*-ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ*

**ចែកជាធាតុ**

*-ចេតសិក៧ ជាធម្មធាតុ*

*-ចិត្តដួងនេះ ជាជីវ្ហាវិញ្ញាណធាតុ*

**ចែកជាអាយតន**

*-ចេតសិក៧ ជាធម្មាយតន*

*-ចិត្តដួងនេះ ជាមនាយតន*

**ចែកជាសច្ច**

*-ចេតសិក៧ ជាទុក្ខសច្ច*

*-ចិត្តដួងនេះ ជាទុក្ខសច្ច ។*

# ធម៌អប់រំចិត្ត

បិ.៥៧.ទំ.១៥៥.ឧព្វិរីថេរស្តីអំពី សេចក្តីសោកគ្របសង្កត់ចិត្ត

*ម្នាលនាងឧព្វិរី នាងកន្ទក់កន្ទេញក្នុងព្រៃថា ម្នាលជីវៈ មាសម្តាយ ដូច្នេះនាងចូរដឹងខ្លួន កូនស្រីរបស់នាងទាំងអស់ ៨៤,០០០ មានឈ្មោះថា ជីវៈដូចគ្នា ត្រូវគេដុតក្នុងឈាបនដ្ឋាន នេះ បណ្តាកូនស្រីទាំងអស់នោះ តើនាងសោកចំពោះកូនស្រីណា។ សរគឺ សេចក្តីសោកអាស្រ័យនៅហឫទ័យរបស់ខ្ញុំព្រះអង្គ ជារបស់ ដែលបានឃើញដោយកម្រ បានដកចេញហើយព្រះអង្គ បាន បន្ទោបង់នូវសេចក្តីសោក ព្រោះកូនស្រីរបស់ខ្ញុំព្រះអង្គ ដែលត្រូវ សេចក្តីសោកគ្របសង្កត់ហើយ ។ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គនោះ មានសរដកហើយ ជាអ្នកមិនមានសេចក្តីស្រេកឃ្លាន បានរំលត់ ទុក្ខហើយ ខ្ញុំព្រះអង្គ សូមដល់នូវព្រះពុទ្ធជាអ្នកប្រាជ្ញផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈ ។*

*ពាក្យគួរចេះ*

| |
|---|
| ជីវិតរស់នៅ មិនមែនដើម្បីស្លាប់តែម្យ៉ាងនោះទេ |

*ពាក្យកំសត់*

| |
|---|
| ពាក្យថា (ស្លាប់)ជាបុរាណពាក្យមានយូរណាស់មកហើយ |

## **អកុសលវិបាកចិត្តដួងទី៥**

**៥-ទុក្ខសហគតំ កាយវិញ្ញាណំ អកុសលវិបាកចិត្តំ**

*កាយវិញ្ញាណ ដែលជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយគ្នានឹងទុក្ខវេទនា មានការដឹងនូវផោដ្ឋព្វៈ មិនល្អ ។*

**មានចេតសិកប្រកប៧គឺ**

*សព្វចិត្តសាធារណចេតសិក៧*

**ចែកជាខន្ធ**

*-វេទនាចេតសិក ជាវេទនាខន្ធ*

*-សញ្ញាចេតសិក ជាសញ្ញាខន្ធ*

*-ចេតសិក៥ ជាសង្ខារក្ខន្ធ*

*-ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ*

**ចែកជាធាតុ**

*-ចេតសិក៧ ជាធម្មធាតុ*

*-ចិត្តដួងនេះ ជាកាយវិញ្ញាណធាតុ*

**ចែកជាអាយតន**

*-ចេតសិក៧ ជាធម្មាយតន*

*-ចិត្តដួងនេះ ជាមនាយតន*

**ចែកជាសច្ច**

*-ចេតសិក៧ ជាទុក្ខសច្ច*

*-ចិត្តដួងនេះ ជាទុក្ខសច្ច ។*

# ធម៌អប់រំចិត្ត

បិ.៥៧.ទំ.១៥៦. សេលាថេរី ស្ដីអំពី កាម ឧបមាដូចលំពែង

*(មារមានចិត្តបាបពោលថា) ការរលាស់ខ្លួនចេញ (ចាកភព) ក្នុងលោករបស់នាងមិនមានទេ នាងនឹងធ្វើអ្វីដោយវិវេក នាងចូរបរិភោគនូវតម្រេក ដែលអាស្រ័យនូវកាមទាំងឡាយ កុំឱ្យក្ដៅក្រហាយជាខាងក្រោយឡើយ ។ ( សេលាភិក្ខុនីពោលថា ) កាមទាំងឡាយមានឧបមាដោយលំពែង និងដែកស្រួច ជាគ្រឿងកាប់ចិញ្ច្រាំនូវឧបាទានក្ខន្ធទាំងឡាយ អ្នកឯងពោល (សំដៅ) តម្រេកក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះ ជាទីអផ្សុក អាត្មាអញទេតើ ។ ការរីករាយក្នុងអារម្មណ៍ទាំងពួង យើងបានកំចាត់ចេញហើយ គំនរងងឹតយើងបានទំលុះទំលាយហើយ ម្នាលមារមានចិត្តបាប អ្នកឯងចូរដឹងយ៉ាងនេះចុះ ម្នាលមារថោកទាប អ្នកឯងយើងកំចាត់ចេញបានហើយ ។*

<u>*ពាក្យគួរគិត*</u>

➪...**ជីវិតមនុស្សកើតមកដោយសារអ្វី**?

# អកុសលវិបាកចិត្តដួងទី៦

## ៦-ឧបេក្ខាសហគតំ មនោធាតុ អកុសលវិបាកចិត្តំ

*មនោធាតុ ដែលជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយគ្នានឹងឧបេក្ខាវេទនា គឺធ្វើសម្បដិច្ឆន្នកិច្ច ទទួលនូវអារម្មណ៍ឯណានីមួយៗក្នុងបញ្ចទ្វារ ។*

### មានចេតសិកប្រកប១០គឺ

*- អញ្ញសមានាចេតសិក១០ (វៀរ វិរិយ បីតិ ឆន្ទៈ)*

### ចែកជាខន្ធ

| | |
|---|---|
| *-វេទនាចេតសិក* | *ជាវេទនាខន្ធ* |
| *-សញ្ញាចេតសិក* | *ជាសញ្ញាខន្ធ* |
| *-ចេតសិក៨* | *ជាសង្ខារក្ខន្ធ* |
| *-ចិត្តដួងនេះ* | *ជាវិញ្ញាណក្ខន្ធ* |

### ចែកជាធាតុ

| | |
|---|---|
| *-ចេតសិក១០* | *ជាធម្មធាតុ* |
| *-ចិត្តដួងនេះ* | *ជាមនោធាតុ* |

### ចែកជាអាយតន

| | |
|---|---|
| *-ចេតសិក១០* | *ជាធម្មាយតន* |
| *-ចិត្តដួងនេះ* | *ជាមនាយតន* |

### ចែកជាសច្ច

| | |
|---|---|
| *-ចេតសិក១០* | *ជាទុក្ខសច្ច* |
| *-ចិត្តដួងនេះ* | *ជាទុក្ខសច្ច ។* |

# ធម៌អប់រំចិត្ត

បិ.៥៧.ទំ.១៥៨.ភទ្ទកាបិលានីថេរីស្តីអំពីការតំកល់ចិត្តមាំល្អ

*(ភទ្ទកាបិលានីពោលថា) ព្រះថេរៈឈ្មោះកស្សបៈ ជាបុត្តពុទ្ធទាយាទ មានចិត្តតម្កល់មាំល្អ លោកបានដឹងនូវបុព្វេនិវាសទាំងឃើញឋានសួគ៌ និងអបាយ លំដាប់អំពីនោះមក លោកបានដល់នូវធម៌ ជាទីអស់ទៅនៃជាតិ បានសម្រេចនូវអភិញ្ញា ជាអ្នកប្រាជ្ញ ជាព្រាហ្មណ៍ បានសម្រេចវិជ្ជា ៣ ដោយវិជ្ជា ៣ នោះ។ ព្រះថេរី ឈ្មោះ ភទ្ទកាបិលានី ក៏យ៉ាងនោះដែរ បានសម្រេចវិជ្ជា ៣ ញុំាងមច្ចុឱ្យសាបសូន្យឈ្នះមារព្រមទាំងវាហនៈ ហើយទ្រទ្រង់រាងកាយជាទីបំផុត ។ យើងទាំងពីរនាក់ បានឃើញទោសក្នុងលោកហើយមកបួស យើងទាំងនោះ ជាព្រះខីណាស្រព បានទូន្មានខ្លួនហើយ ជាអ្នកមានចិត្តត្រជាក់បាននិព្វានហើយ ។*

<u>*ពាក្យគួរចេះ*</u>

| |
|---|
| **មនុស្សសាងការងារ ទើបការងារសាងមនុស្ស** |

## អកុសលវិបាកចិត្តដួងទី៧

**៧-ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អកុសលវិបាកចិត្តំ** មនោវិញ្ញាណធាតុ ដែលជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា មានការដឹងនូវអារម្មណ៍មិនល្អ ធ្វើកិច្ចបាន ៥ យ៉ាង ។ (បដិសន្ធិកិច្ច , ភវង្គកិច្ច , ចុតិកិច្ច , សន្តីរណកិច្ច , តទាលម្ពណកិច្ច) ។

### មានចេតសិកប្រកប ១០ គឺ

- អញ្ញសមានាចេតសិក ១០ (វៀរ វិរិយ បីតិ ឆន្ទ)

### ចែកជាខន្ធ

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក៨ ជាសង្ខារក្ខន្ធ

-ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ

### ចែកជាធាតុ

-ចេតសិក ១០ ជាធម្មធាតុ

-ចិត្តដួងនេះ ជាមនោវិញ្ញាណធាតុ

### ចែកជាអាយតន

-ចេតសិក១០ ជាធម្មាយតន

-ចិត្តដួងនេះ ជាមនាយតន

### ចែកជាសច្ច

- ចេតសិក១០ ជាទុក្ខសច្ច

-ចិត្តដួងនេះ ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

**បិ.៥៧.ទំ.១៥៩. វិមលថេរី ស្តីអំពីដឹងខ្លួន,កែខ្លួន,ខ្លួនល្អ**

*អាត្មាអញស្រវឹង រឹងប៉្រឹង ដោយការសរសើរគុណផង ដោយរូបសម្បត្តិផង ដោយលំអដ៏លើសផង ដោយយសផង ដោយវ័យផង បានមើលងាយពួកស្រីដទៃ ។ អាត្មាអញស្អិតស្អាងរាងកាយនេះ ឲ្យវិចិត្រល្អឲ្យជាទីរាក់ទាក់នៃជនពាលហើយឈរក្បែរទ្វារផ្ទះនៃស្រីពេស្យាដូចជាព្រានម្រឹកដាក់អន្ទាក់ ។ អាត្មាអញសម្តែងគ្រឿងប្រដាប់ និងអវយវៈដ៏កំបាំង ឲ្យជាក់ច្បាស់ជាច្រើនសើចក្អាកក្អាយ បានធ្វើមាយាច្រើនយ៉ាង (ដើម្បី) ញ៉ាំងជនពាលជាច្រើន(ឲ្យស្រើបស្រាល) ។ ក្នុងថ្ងៃនេះ អាត្មាអញនោះបានកោរសក់ ដណ្តប់សង្ឃាដី ដើរទៅបិណ្ឌបាតរួចអង្គុយក្រោមម្លប់ឈើ ជាអ្នកបាននូវធម៌ដែលមិនមានវិតក្កៈ។ គ្រឿងប្រកបទាំងពួង ទោះជាទិព្វក្តី ជារបស់មនុស្សក្តី អាត្មាអញបានផ្តាច់ផ្តិលហើយ អាត្មាអញបានញ៉ាំងអាសវៈទាំងពួង ឲ្យអស់ហើយជាអ្នកមានចិត្តត្រជាក់ រំលត់ទុក្ខហើយ ។*

*ពាក្យគួរគិត*

**➪...មនុស្សសាងល្អ ទើបសេចក្តីល្អសាងមនុស្ស**

## តារាងអកុសលវិបាកចិត្ត៧ដួង

អកុសលវិបាក៧ដួង
- ឧបេក្ខាសហគត៤
  - ចក្ខុវិញ្ញាណ ១
  - សោតវិញ្ញាណ ១
  - ឃានវិញ្ញាណ១
  - ជិវ្ហាវិញ្ញាណ១
- ទុក្ខសហគត១
  - កាយវិញ្ញាណ
- ឧបេក្ខាសហគត២
  - សម្បដិច្ឆន្នចិត្ត១
  - សន្តីរណចិត្ត ១

## ពាក្យថា អហេតុកកុសលវិបាកចិត្ត

ពាក្យថា កុសលវិបាកចិត្ត មកពី (កុសល+វិបាក + ចិត្ត) ប្រែមកថា ចិត្តជាផលដ៏ផ្អិនរបស់កុសលកម្ម។ បានសេចក្តីថា ចិត្តនេះជាផលរបស់ចិត្តមុន ដោយអំណាចតំណារនៃចិត្តមុនៗ ដែលបានសន្សំនូវកម្មផ្សេងៗ។ ឧទាហរណ៍ដូចប្រក្រតីនៃជីវិតប្រចាំថ្ងៃ មានការឃើញរូបល្អ រូបល្អនេះ ដែលប៉ះខ្ទប់នឹងចក្ខុបសាទ ព្រមទាំង ពេលនោះ ក៏មានឱភា គឺពន្លឺជាទីអាស្រ័យ ហើយក៏ចក្ខុវិញ្ញាណកើតឡើង ។ នេះគ្រាន់តែជាសេចក្តីមួយ ដើម្បីបញ្ជាក់ឱ្យឃើញថាអ្វីៗដែលកើតឡើង ដូចជាការឃើញរូបល្អ ពេលនេះ មិនមែនកើតឡើងដោយអត់ហេតុ អត់បច្ច័យទេ គឺកើតឡើង

ដោយអាស្រ័យហេតុបច្ច័យទាំងអស់។ សួរថា: កុសលវិបាកចិត្ត គឺជាអហេតុកចិត្ត បានសេចក្តីថា ជាចិត្តដែលកើតឡើងដោយមិនអាស្រ័យ ហេតុ ចុះហេតុអ្វីបានសម្តែងថា សូម្បីមានការឃើញរូបក៏អាស្រ័យហេតុបច្ច័យដែរ ? ចម្លើយ៖ ដែលសម្តែងអំពីហេតុក្នុងទីនេះ មិនមែនសំដៅដល់ហេតុទាំង ៦ នោះទេ គឺសំដៅដល់ឧប្បត្តិហេតុផ្សេងៗ ដូចជាចិត្តឃើញកើតឡើង ពេលនោះលោភហេតុក្តី ទាំងទោសហេតុក្តី មោហហេតុក្តី ទាំងអលោភហេតុក្តី ទាំងអទោសហេតុក្តី ទាំងអមោហហេតុក្តី ក៏មិនមានកើតក្នុងពេលនោះដែរ។ តែហេតុពេលនោះ ដូចជាចក្ខុវិញ្ញាណ ដែលកើតឡើង ប្រសិនបើរូបារម្មណ៍ (វណ្ណរូប) មិនមកកាន់គន្លងនៃចក្ខុបសាទទេ ចក្ខុវិញ្ញាណក៏មិនអាចកើតឡើងបាន តែបើមានរូបមកកាន់គន្លងនៃចក្ខុបសាទហើយ តែក្នុងពេលនោះមិនមាននូវពន្លឺចក្ខុវិញ្ញាណ ក៏មិនអាចកើតឡើងបាន ទាំងនេះអ្នកសិក្សាគប្បីជ្រាប តើមិនមែនជាហេតុបច្ច័យទេឬ ? ប៉ុន្តែពេលឃើញរូបល្អ ឮសម្លេងល្អ ធុំក្លិនល្អ ដឹងរសល្អ ដឹងផោដ្ឋព្វៈល្អ និងដឹងនូវរឿងល្អ គប្បីជ្រាបថា នេះជាផលរបស់កុសលកម្ម ដែលបានសន្សំធ្វើហើយ អំពីកាលមុនទើបចិត្តនេះឈ្មោះថា អហេតុក-កុសលវិបាកចិត្ត ។

# អហេតុកកុសលវិបាកចិត្ត៨ដួង

## អហេតុកកុសលវិបាកចិត្ត ដួងទី១

### ១-ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ កុសលវិបាកចិត្តំ

*ចក្ខុវិញ្ញាណ ដែលជាកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយគ្នានឹងឧបេក្ខាវេទនា មានការឃើញនូវរូបល្អ។*

**មានចេតសិកប្រកប៧គឺ**

*-សព្វចិត្តសាធារណចេតសិក ៧*

**ចែកជាខន្ធ**

| | |
|---|---|
| *-វេទនាចេតសិក* | *ជាវេទនាខន្ធ* |
| *-សញ្ញាចេតសិក* | *ជាសញ្ញាខន្ធ* |
| *-ចេតសិក៥* | *ជាសង្ខារក្ខន្ធ* |
| *-ចិត្តដួងនេះ* | *ជាវិញ្ញាណក្ខន្ធ* |

**ចែកជាធាតុ**

| | |
|---|---|
| *-ចេតសិក៧* | *ជាធម្មធាតុ* |
| *-ចិត្តដួងនេះ* | *ជាចក្ខុវិញ្ញាណធាតុ* |

**ចែកជាអាយតន**

| | |
|---|---|
| *-ចេតសិក៧* | *ជាធម្មាយតន* |
| *-ចិត្តដួងនេះ* | *ជាមនាយតន* |

**ចែកជាសច្ច**

| | |
|---|---|
| *-ចេតសិក៧* | *ជាទុក្ខសច្ច* |
| *-ចិត្តដួងនេះ* | *ជាទុក្ខសច្ច ។* |

# ធម៌អប់រំចិត្ត

**បិ.៥៦.ទំ.១៣៥. សុភូតិត្ថេរ ស្ដីអំពីភ្លៀងកិលេស**

*ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា អ្នកទាំងឡាយ ចូរស្ដាប់នូវគាថាទាំងឡាយ ប្រកបដោយប្រយោជន៍របស់ព្រះថេរទាំងឡាយ អ្នកមានចិត្តចម្រើនហើយ កាលបន្លឺឡើងដូចជាសីហៈ ជាសត្វមានចង្កូម ដែលបន្លឺទៀបច្រកនៃភ្នំ ព្រះថេរៈទាំងឡាយ តាមនាម តាមគោត្រ តាមវិហារធម៌ តាមអធ្យាស្រ័យប្រកបដោយប្រាជ្ញាជាបុគ្គលមិនខ្ជិលច្រអូស ចម្រើនវិបស្សនាក្នុងទីនោះៗ បានពាល់ត្រូវអច្ចុតបទគឺព្រះនិព្វាន ពិចារណានូវគុណសម្បត្តិដែលលោកបានធ្វើស្រេចហើយ បានសម្ដែងហើយនូវសេចក្ដីដូចតទៅនេះ ។*

*(ព្រះសុភូតិត្ថេរពោលថា) នែភ្លៀងខ្ទមរបស់អាត្មា បានបិទបាំងហើយជាសុខ មិនមានខ្យល់ អ្នកចូរបង្អុរតាមសប្បាយចុះ ចិត្តរបស់អាត្មាអញតម្កល់ទុកល្អហើយ ជាចិត្តរួចស្រឡះ (ចាកអាសវៈ) អាត្មាមានព្យាយាម ដុតកំដៅកិលេសជាប្រក្រតី ម្នាលភ្លៀង អ្នកចូរបង្អុរមកចុះៗ ឮថាព្រះសុភូតិត្ថេរ មានអាយុបានពោល គាថា ដោយប្រការដូច្នេះៗ*

# អហេតុកកុសលវិបាកចិត្តដួងទី២

## ២-ឧបេក្ខាសហគតំ សោតវិញ្ញាណំ កុសលវិបាកចិត្តំ

*សោតវិញ្ញាណ ដែលជាកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយគ្នានឹងឧបេក្ខាវេទនាមានការឮនូវសំឡេងល្អ។*

**មានចេតសិកប្រកប៧គឺ**

- *សព្វចិត្តសាធារណចេតសិក ៧*

**ចែកជាខន្ធ**

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាណចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ៥ | ជាសង្ខារក្ខន្ធ |
| -ចិត្តដួងនេះ | ជាវិញ្ញាណក្ខន្ធ |

**ចែកជាធាតុ**

| | |
|---|---|
| -ចេតសិក៧ | ជាធម្មធាតុ |
| -ចិត្តដួងនេះ | ជាសោតវិញ្ញាណធាតុ |

**ចែកជាអាយតន**

| | |
|---|---|
| -ចេតសិក៧ | ជាធម្មាយតន |
| -ចិត្តដួងនេះ | ជាមនាយតន |

**ចែកជាសច្ច**

| | |
|---|---|
| - ចេតសិក៧ | ជាទុក្ខសច្ច |
| -ចិត្តដួងនេះ | ជាទុក្ខសច្ច ។ |

# ធម៌អប់រំចិត្ត

**បិ.៥៦.ទំ.១៨៦. សិរកត្ថេរ ស្តីអំពីជាងផ្ទះគឺតណ្ហា**

*ផ្ទះគឺអត្តភាពទាំងឡាយ (ដែលកើត ) រឿយៗក្នុងភពនោះ ជារបស់មិនទៀង ឥឡូវនេះអាត្មាអញ កំពុងតែខំស្វែងរកជាង គឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព ការកើតរឿយៗ ជាហេតុនាំមកនូវសេចក្តីទុក្ខ ។ នែជាងផ្ទះ អ្នកគឺយើងបានឃើញច្បាស់ហើយ អ្នកនឹងធ្វើផ្ទះទៀតមិនបានឡើយ ឆ្អឹងជំនីគឺកិលេសទាំងអស់របស់អ្នក យើងបានបំបាក់អស់ហើយ ទាំងហោជាង គឺអវិជ្ជាទៀតសោត យើងបានរុះរើចោលអស់ហើយ ចិត្តដែលយើងធ្វើឲ្យវិងស្ងួត ក៏នឹងរលត់ក្នុងភពនេះឯង ។*

*ពាក្យគួរយល់ដឹង*

**ជីវិតកើតមកដោយសារបុណ្យ**

*ពាក្យគួរឆ្ងល់*

**⇨...ពាក្យថាបុណ្យ ច្បាស់សេចក្តីថាម៉េចទៅហ្ន៎** !

## អហេតុកកុសលវិបាកចិត្តដួងទី៣

### ៣.ឧបេក្ខាសហគតំ ឃានវិញ្ញាណំ កុសលវិបាកចិត្តំ

*ឃានវិញ្ញាណដែលកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយគ្នានឹងឧបេក្ខាវេទនា មានការធុំនូវក្លិនល្អ ។*

**មានចេតសិកប្រកប ៧គឺ**

*-សព្វចិត្តសាធារណចេតសិក ៧*

**ចែកជាខន្ធ**

| | |
|---|---|
| *-វេទនាចេតសិក* | *ជាវេទនាខន្ធ* |
| *-សញ្ញាចេតសិក* | *ជាសញ្ញាខន្ធ* |
| *-ចេតសិក ៥* | *ជាសង្ខារក្ខន្ធ* |
| *-ចិត្តដួងនេះ* | *ជាវិញ្ញាណក្ខន្ធ* |

**ចែកជាធាតុ**

| | |
|---|---|
| *-ចេតសិក ៧* | *ជាធម្មធាតុ* |
| *-ចិត្តដួងនេះ* | *ជាឃានវិញ្ញាណធាតុ* |

**ចែកជាអាយតន**

| | |
|---|---|
| *-ចេតសិក៧* | *ជាធម្មាយតន* |
| *-ចិត្តដួងនេះ* | *ជាមនាយតន* |

**ចែកជាសច្ច**

| | |
|---|---|
| *- ចេតសិក ៧* | *ជាទុក្ខសច្ច* |
| *-ចិត្តដួងនេះ* | *ជាទុក្ខសច្ច ។* |

# ធម៌អប់រំចិត្ត

## *បិ.៥៦.ទំ.១៨៧. ឥសិទិន្នត្ថេរ ស្តីអំពី មិនដឹងធម៌ពិត*

*ពួកឧបាសក អ្នកទ្រទ្រង់ព្រះបរិយត្តិធម៌ ដែលខ្ញុំជួបហើយ បាននិយាយថា កាមទាំងឡាយជារបស់មិនទៀង តែពួកឧបាសកនោះ នៅតែត្រេកអរក្រៃពេកក្នុងកែវមណី និងកណ្ឌលទាំងឡាយផង ជាអ្នកអាឡោះអាល័យក្នុងកូននិងប្រពន្ធផង ។ ពួកឧបាសកទាំងនោះ មិនទាន់ដឹងធម៌ពិតទេ គ្រាន់តែចេះនិយាយថា កាមទាំងឡាយជារបស់មិនទៀង ឧបាសកទាំងនោះ មិនទាន់មានកម្លាំងញាណ ដើម្បីកាត់ផ្តាច់នូវរាគៈទេ ព្រោះហេតុនោះ បាននៅជាប់ស្អិតចំពោះកូនប្រពន្ធ និងទ្រព្យសម្បត្តិ ។*

*<u>ពាក្យគួរចេះ</u>*

**មនុស្សយើងគ្រប់គ្នា កុំភ្លេចគុណបុណ្យ**

*<u>ពាក្យកាព្យ</u>*

បុណ្យបូកនិងបុណ្យកុំបីបាត់ បាបនោះគួរបិទកុំបីបើក
រឿងបានរឿងបង់គង់កំរើក រៀមច្បងគួរលើកបត់បូជា។

*ដោយឧបាសក ជឹម កាន*

## អហេតុកកុសលវិបាកចិត្តដួងទី ៤

**៤. ឧបេក្ខាសហគតំ ជីវ្ហាវិញ្ញាណំ កុសលវិបាកចិត្តំ**

*ជីវ្ហាវិញ្ញាណ ដែលជាកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយគ្នានឹងឧបេក្ខាវេទនា មានការដឹងនូវរសល្អ។*

### មានចេតសិកប្រកប ៧ គឺ

*-សព្វចិត្តសាធារណចេតសិក ៧*

### ចែកជាខន្ធ

*-វេទនាចេតសិក ជាវេទនាខន្ធ*

*-សញ្ញាចេតសិក ជាសញ្ញាខន្ធ*

*-ចេតសិក៥ ជាសង្ខារក្ខន្ធ*

*-ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ*

### ចែកជាធាតុ

*-ចេតសិក ៧ ជាធម្មធាតុ*

*-ចិត្តដួងនេះ ជាជីវ្ហាវិញ្ញាណធាតុ*

### ចែកជាអាយតន

*-ចេតសិក៧ ជាធម្មាយតន*

*-ចិត្តដួងនេះ ជាមនាយតន*

### ចែកជាសច្ច

*-ចេតសិក ៧ ជាទុក្ខសច្ច*

*-ចិត្តដួងនេះ ជាទុក្ខសច្ច ។*

# ធម៌អប់រំចិត្ត

**បិ.៥៦.ទំ.១៨៧.សម្ពុលកច្ចានត្ថេរ ស្តីអំពីនៅម្នាក់ឯងមិនមានភ័យ**

*ភ្លៀងបង្អុរចុះផង មេឃគ្រហឹមលាន់គ្រឹលៗផង (ក្នុងពេលនោះ) អាត្មាអញនៅតែម្នាក់ឯងក្នុងរូងភ្នំ ដែលគួរខ្លាច តែម្នាក់ឯងភ័យក្តី សេចក្តីតក់ស្លុតក្តី សេចក្តីព្រឺរោមក្តីមិនមានទេ ។ កាលអាត្មាអញ នៅម្នាក់ឯងក្នុងរូងភ្នំ ដែលគួរឲ្យខ្លាចភ័យក្តី សេចក្តីតក់ស្លុកក្តី សេចក្តីព្រឺរោមក្តីមិនមានឡើយ នេះជាធម្មតា របស់អាត្មាអញ ។*

*ពាក្យគួរគិត*

**ខ្លឹមសារមនុស្សនៅត្រង់ណា** ?

*ពាក្យកាព្យ*

រូបសល្អរាងគួរស្រលាញ់ តែចាញ់ល្អចិត្តគំនិតជា
មិនយូរប៉ុន្មានរូបជរា ឯចិត្តល្អជាមិនចាស់ឡើយ។

*ដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស*

## អហេតុកកុសលវិបាកចិត្តដួងទី ៥

## ៥-សុខសហគតំ កាយវិញ្ញាណំ កុសលវិបាកចិត្តំ

*កាយវិញ្ញាណ ដែលជាកុសលវិបាកចិត្តប្រព្រឹត្តជាមួយនឹងសុខ*

*វេទនា មានការដឹងនូវផោដ្ឋព្វៈល្អ។*

### មានចេតសិកប្រកប៧គឺ

- សព្វចិត្តសាធារណចេតសិក ៧

### ចែកជាខន្ធ

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ៥ | ជាសង្ខារក្ខន្ធ |
| - ចិត្តដួងនេះ | ជាវិញ្ញាណក្ខន្ធ |

### ចែកជាធាតុ

| | |
|---|---|
| -ចេតសិក ៧ | ជាធម្មធាតុ |
| -ចិត្តដួងនេះ | ជាកាយវិញ្ញាណធាតុ |

### ចែកជាអាយតន

| | |
|---|---|
| -ចេតសិក៧ | ជាធម្មាយតន |
| -ចិត្តដួងនេះ | ជាមនាយតន |

### ចែកជាសច្ច

| | |
|---|---|
| -ចេតសិក ៧ | ជាទុក្ខសច្ច |
| -ចិត្តដួងនេះ | ជាទុក្ខសច្ច ។ |

# ធម៌អប់រំចិត្ត

**បិ.៥៦.ទំ. ១៩១. កុមារកស្សបត្ថេរ ស្តីអំពីដឹងនូវធម៌ពិត**

*ឱ!ព្រះពុទ្ធ ឱ!ព្រះធម៌ ឱ!សម្បទា របស់ព្រះសាស្តានៃយើងទាំងឡាយ ដែលសាវ័កនឹងធ្វើឲ្យជាក់ច្បាស់នូវធម៌ប្រាកដដូច្នោះ ។ សក្កាយ គឺបញ្ចុបាទានក្ខន្ធ អាត្មាអញ បានហើយក្នុងកប្បទាំងឡាយរាប់មិនបាន រាងកាយនេះជាទីបំផុត របស់បញ្ចុបាទានក្ខន្ធទាំងនោះរាងកាយនេះ ជាខាងក្រោយរបស់បញ្ចុបាទានក្ខន្ធទាំងនោះ សង្សារប្រកបដោយជាតិ និងមរណៈ ឥឡូវនេះ ភពថ្មីមិនមានទេ ។*

*<u>ពាក្យគួរដឹង</u>*

| |
|---|
| ខ្លឹមសារមនុស្ស មិនមែននៅលើមានត្រង់ទ្រព្យច្រើនទេ |

*<u>ពាក្យគួរពិចារណា</u>*

| |
|---|
| ទ្រព្យសម្បត្តិជាទីស្រលាញ់ពេញចិត្តរបស់មនុស្សទាំងឡាយ តែសម្បត្តិក៏អាចប្រហារម្ចាស់ឲ្យស្លាប់បានផងដែរ ។ |

## អហេតុកកុសលវិបាកចិត្តដួងទី៦

**៦-ឧបេក្ខាសហគតំ មនោធាតុ កុសលវិបាកចិត្តំ**

មនោធាតុ ដែលជាកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា មានការដឹងអារម្មណ៍ល្អក្នុងទ្វារទាំង ៥ ណាមួយ ។

**មានចេតសិកប្រកប១០ គឺ**

-អញ្ញសមានាចេតសិក១០ (វៀរវិរិយ បីតិ ឆន្ទ)

**ចែកជាខន្ធ**

-វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៨ ជាសង្ខារក្ខន្ធ

-ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ

**ចែកជាធាតុ**

-ចេតសិក ១០ ជាធម្មធាតុ

-ចិត្តដួងនេះ ជាមនោធាតុ

**ចែកជាអាយតន**

-ចេតសិក១០ ជាធម្មាយតន

-ចិត្តដួងនេះ ជាមនាយតន

**ចែកជាសច្ច**

-ចេតសិក ១០ ជាទុក្ខសច្ច

-ចិត្តដួងនេះ ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

**បិ.៥៦.ទំ.១៩២. មោឃរាជត្ថេរ ស្តីអំពីរូបអាក្រក់តែចិត្តល្អ**

*(ព្រះសាស្តា ទ្រង់សួរថា) ម្នាលមោឃរាជ ជាអ្នកមានសម្បុរអាក្រក់តែមានចិត្តល្អ អ្នកជាភិក្ខុមានចិត្តតម្កល់មាំរឿយៗ អស់រាត្រីទាំងឡាយ ក្នុងកាលត្រជាក់ប្រកបដោយហេមន្តរដូវ តើអ្នកនឹងធ្វើដោយប្រការដូចម្តេច ?*

*មោឃរាជត្ថេរក្រាបទូលថា ខ្ញុំព្រះអង្គបានឮដូច្នេះថា ដែនមគធៈទាំងមូល ជាដែនមានសន្ទូងបរិបូរណ៍ ពួកភិក្ខុដទៃ មានការរស់នៅជាសុខ (ដោយកម្រាល និងគ្រឿងស្លៀកដណ្តប់ដ៏ល្អ) យ៉ាងណា ខ្ញុំព្រះអង្គ (ក្រាល) បិទបាំងស្លឹកឈើ សម្រេចនូវការដេក (យ៉ាងនោះដែរ)។*

*<u>ពាក្យគួរចេះ</u>*

| |
|---|
| ជីវិតរស់នៅមានតម្លៃ ព្រោះមានកាមគុណ ៥<br>(នេះជាទ្រឹស្តីរបស់មនុស្សល្ងង់) |

*<u>ពាក្យដាស់តឿន</u>*

គុណធម៌មិនសំខាន់ខ្លាំងណាស់ សម្រាប់មនុស្សគ្រប់គ្នា មនុស្សគ្រប់គ្នាកាលបើខ្វះនូវគុណធម៌ហើយ ចំណេះដែលចេះប្រៀបបីដូចបិសាច ធ្វើឲ្យបុគ្គលអ្នកចេះនោះ វិនាសហិនហោច ព្រោះតែចេះខ្វះគុណធម៌នោះឯង ។...⇦

## អហេតុកកុសលវិបាកចិត្តដួងទី៧

**៧.សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកុសលវិបាកចិត្តំ** *មនោវិញ្ញាណធាតុ ដែលជាអហេតុកកុសល-វិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា ធ្វើកិច្ចនៅក្នុងទ្វារទាំង ៦ ។*

### មានចេតសិកប្រកប១១ គឺ

*-អញ្ញសមានាចេតសិក១១ (វៀរវិរិយ ឆន្ទ)*

### ចែកជាខន្ធ

*-វេទនាចេតសិក ជាវេទនាខន្ធ*

*-សញ្ញាចេតសិក ជាសញ្ញាខន្ធ*

*-ចេតសិក ៩ ជាសង្ខារក្ខន្ធ*

*-ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ*

### ចែកជាធាតុ

*-ចេតសិក ១១ ជាធម្មធាតុ*

*-ចិត្តដួងនេះ ជាមនោវិញ្ញាណធាតុ*

### ចែកជាអាយតន

*-ចេតសិក១១ ជាធម្មាយតន*

*-ចិត្តដួងនេះ ជាមនាយតន*

### ចែកជាសច្ច

*-ចេតសិក ១១ ជាទុក្ខសច្ច*

*-ចិត្តដួងនេះ ជាទុក្ខសច្ច ។*

# ធម៌អប់រំចិត្ត

**បិ.៥៦.ទំ.១៩៧. ពាកុលត្ថេរ ស្ដីអំពី ធ្វើយ៉ាងណា និយាយយ៉ាងនោះ**

*បុគ្គលណា (មិនធ្វើ) នូវអំពើដែលគួរធ្វើក្នុងកាលមុន ហើយចង់ធ្វើក្នុងកាលក្រោយវិញបុគ្គលនោះ រមែងឃ្លាតចាកឋានៈ ជាសុខផង តែងក្ដៅក្រហាយរឿយៗក្នុងកាល ជាខាងក្រោយផង ។ បុគ្គលធ្វើអំពើណាត្រូវនិយាយតែអំពើនោះ មិនធ្វើអំពើណាមិនត្រូវនិយាយអំពើនោះឡើយ បណ្ឌិតទាំងឡាយ តែងកំណត់ដឹងច្បាស់នូវបុគ្គលកាលមិនធ្វើបានតែនិយាយ ។ សេចក្ដីទុក្ខបានរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងហើយ ជាគុណជាតិមិនមានសេចក្ដីសោក ប្រាសចាកធូលី ជាទីក្សេមក្សាន្ត នាំមកនូវសេចក្ដីសុខ ដោយប្រពៃមែនពិត ។*

*ពាក្យគួរចេះ*

**ខ្លឹមសារមនុស្សនៅត្រង់មានគុណធម៌**

*ពាក្យគួរដឹង*

**➪...គុណធម៌ហ្នឹងហើយដែលធ្វើឲ្យមនុស្ស ប្លែកពីសត្វតិរច្ឆាន**

## អហេតុកកុសលវិបាកចិត្តដួងទី៨

**៨-ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុកកុសលវិបាកចិត្តំ** មនោវិញ្ញាណធាតុ ដែលជាអហេតុកកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា មានការកើតនៅក្នុងទ្វារទាំង ៦ ក៏មាន កើតក្រៅទ្វារ ៦ ក៏មាន ។

**មានចេតសិកប្រកប១០ គឺ**

-អញ្ញសមានាចេតសិក ១០ (វៀរ វិរិយ បីតិ ឆន្ទ)

**ចែកជាខន្ធ**

- វេទនាចេតសិក ជាវេទនាខន្ធ

-សញ្ញាចេតសិក ជាសញ្ញាខន្ធ

-ចេតសិក ៨ ជាសង្ខារក្ខន្ធ

-ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ

**ចែកជាធាតុ**

-ចេតសិក ១០ ជាធម្មធាតុ

-ចិត្តដួងនេះ ជាមនោធាតុ

**ចែកជាអាយតន**

-ចេតសិក១០ ជាធម្មាយតន

-ចិត្តដួងនេះ ជាមនាយតន

**ចែកជាសច្ច**

-ចេតសិក ១០ ជាទុក្ខសច្ច

-ចិត្តដួងនេះ ជាទុក្ខសច្ច ។

# ធម៌អប់រំចិត្ត

**បិ.៥៦.ទំ.១៩៧. ធនិយត្ថេរ ស្តីអំពី ស្រឡាញ់ភាពជាសាមណៈ**

*បើបុគ្គលស្រឡាញ់ក្នុងភាពជាសាមណៈ ប្រាថ្នាដើម្បីរស់នៅស្រួលមិនគប្បីមើលងាយចីវរ ទឹកនិងភោជន ជារបស់សង្ឃទេ ។ បើបុគ្គលស្រឡាញ់ភាពជាសមណៈ ប្រាថ្នារស់នៅស្រួល គប្បីសេពទីដេក និងទីអង្គុយ ដូចជាពស់សេពនូវរន្ធរបស់កណ្តុរ ។ បើបុគ្គលស្រឡាញ់ក្នុងភាពជាសមណៈ ប្រាថ្នាដើម្បីរស់នៅស្រួល គប្បីត្រេកអរដោយបច្ច័យ តាមមានតាមបានផងដែរ គប្បីចម្រើនធម៌ឯកផង ។*

## តារាងអហេតុកកុសលវិបាកចិត្ត ៨ ដួង

អហេតុកកុសលវិបាក ៨
- ឧបេក្ខាសហគត៤
  - ចក្ខុវិញ្ញាណ ១
  - សោតវិញ្ញាណ ១
  - ឃានវិញ្ញាណ ១
  - ជីវ្ហាវិញ្ញាណ ១
- សុខសហគត១ { កាយវិញ្ញាណ១
- ឧបេក្ខាសហគត១ { សម្បដិច្ឆន្នចិត្ត ១
- សោមនស្សសហគត១ { សន្តីរណចិត្ត ១
- ឧបេក្ខាសហគត១ { សន្តីរណចិត្ត ១

# ពាក្យថាអហេតុកកិរិយាចិត្ត

**អហេតុកកិរិយាចិត្ត** មកពី (អហេតុក+កិរិយា+ចិត្ត) ចិត្តជាកិរិយាតែជាអហេតុក ។ សេចក្ដីនេះក្នុងដីកាព្រមទាំងយោជនា លោកពន្យល់ថា ត្រឹមតែជាការធ្វើដោយមិនមានការឲ្យផល ឈ្មោះ ថាកិរិយា ។ បានសេចក្ដីថា ក្នុងអហេតុកចិត្តទាំង ៣ ដួងនេះ មានការត្រឹមតែកើតឡើងប៉ុណ្ណោះ មិនអាចញ៉ាំងកម្ម ដើម្បីនឹងញ៉ាំងនូវវិបាកឲ្យកើតឡើងឡើយ ។ សរុបសេចក្ដីមក គឺមិនមានហេតុមិនមានផល គឺចិត្តនេះកើតឡើងដោយឯងៗ ។

ពាក្យគួរកុំភ្លេច

**កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប**

ពាក្យកាព្យ

| | | |
|---|---|---|
| កើតមកមួយជាតិ | ធាតុមួយចាន | បានធ្វើល្អ |
| បុណ្យកំដរ | តជីវិត | ពិតប្រពៃ |
| ពេលស្លាប់ទៅ | នៅល្អឈ្មោះ | រស់មានន័យ |
| អ្នកដទៃ | លៃលកគ្រាប់ | ច្បាប់គំរូ ។ |

ដោយលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស

## អហេតុកកិរិយាចិត្តដួងទី១

**១-ឧបេក្ខាសហគតំ មនោធាតុ អហេតុកកិរិយាចិត្តំ**

មនោធាតុដែលជាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា កើតតាមបញ្ចទ្វារមុនបញ្ចវិញ្ញាណ, ឬចិត្តនេះហៅម៉្យាងទៀតថា បញ្ចទ្វារាវជ្ជនចិត្ត ក៏បាន ។

**មានចេតសិកប្រកប១០ គឺ**

-អញ្ញសមានាចេតសិក ១០ (វៀរ វិរិយ បីតិ ឆន្ទ)

**ចែកជាខន្ធ**

- វេទនាចេតសិក ជាវេទនាខន្ធ
-សញ្ញាចេតសិក ជាសញ្ញាខន្ធ
- ចេតសិក ៨ ជាសង្ខារក្ខន្ធ
- ចិត្តដួងនេះ ជាវិញ្ញាណក្ខន្ធ

**ចែកជាធាតុ**

-ចេតសិក ១០ ជាធម្មធាតុ
-ចិត្តដួងនេះ ជាមនោធាតុ

**ចែកជាអាយតន**

-ចេតសិក១០ ជាធម្មាយតន
-ចិត្តដួងនេះ ជាមនាយតន

**ចែកជាសច្ច**

-ចេតសិក ១០ ជាទុក្ខសច្ច
-ចិត្តដួងនេះ ជាទុក្ខសច្ច ។

# បញ្ចទ្វារាវជ្ជនចិត្ត

**បញ្ចទ្វារាវជ្ជនៈ** មកពី (បញ្ច + ទ្វារ + អាវជ្ជន) ប្រែថា ពិចារណាអារម្មណ៍ក្នុងបញ្ចទ្វារ គឺទ្វារ៥ ។ ជាកិរិយាមនោធាតុ កាលបើបញ្ចទ្វារាវជ្ជនចិត្ត មិនកើតឡើងសិនទេ វិញ្ញាណ ៥ ក៏មិនអាចកើតឡើងបាន ។ កាលណាចិត្តជាអាវជ្ជនៈកើតរលត់ហើយចិត្តដទៃៗ ក៏កើតឡើងរលត់ជាប់បន្តគ្នារហូតអស់អាយុ នៃអារម្មណ៍ដែលកើតឡើងម្តង នេះហៅថាចិត្តនិយាម គឺសេចក្តីពិតប្រាកដនៃចិត្ត ។

បញ្ចទ្វារាវជ្ជនចិត្តនេះ ជាអហេតុកកិរិយាចិត្តកើតឡើងព្រោះអារម្មណ៍ដែលជារូបមកប៉ះខ្ទប់ នឹងបសាទរូប ជាបច្ច័យ ។ បើបញ្ចទ្វារាវជ្ជនចិត្តទទួលអារម្មណ៍តាមផ្លូវភ្នែក ក៏ហៅថាចក្ខុទ្វារាវជ្ជនៈ បើទទួលអារម្មណ៍តាមផ្លូវត្រចៀក ក៏ហៅថា សោតទ្វារាវជ្ជនៈ បើទីទួលអារម្មណ៍តាមផ្លូវច្រមុះ ក៏ហៅថាឃានទ្វារាវជ្ជនៈ បើទទួលអារម្មណ៍តាមផ្លូវអណ្តាត ក៏ហៅថា ជីវ្ហាទ្វារាវជ្ជនៈ បើទទួលអារម្មណ៍តាមផ្លូវកាយក៏ហៅថា កាយទ្វារាវជ្ជនៈ រួមទាំង ៥ ទ្វារ ហៅថា បញ្ចទ្វារាវជ្ជនចិត្ត ។

(ដីការពន្យល់ថា) ឈ្មោះថា «បញ្ចទ្វារាវជ្ជនៈ» ព្រោះអត្ថថារមែងនឹកដល់អារម្មណ៍ ដែលប៉ះខ្ទប់ត្រូវទ្វារ៥ មានចក្ខុទ្វារជាដើម គឺធ្វើដំណើរនៅក្នុងអារម្មណ៍ ដែលប៉ះខ្ទប់នោះ ឬ ថា

ញ៉ាំងចិត្តសន្តានឲ្យបង្អោនទៅកាន់វិថីចិត្ត មិនព្រមឲ្យប្រព្រឹត្តទៅដោយអំណាចភវង្គបានដល់ចិត្ត គឺអហេតុកមនោធាតុ ចំណែកកិរិយា ។

**លក្ខណាទិចតុករបស់បញ្ចទ្វារាវជ្ជនៈ**

- **ចក្ខុវិញ្ញាណាទិបុរេចល រូបាទិវិជាន ន លក្ខណា** មានការនាំមុខនៃវិញ្ញាណមានចក្ខុវិញ្ញាណជាដើម ហើយដឹងច្បាស់នូវអារម្មណ៍មានរូបជាដើម ជាលក្ខណៈ
- **អាវជ្ជន រសា** មានការរំពឹង ឬនឹករកនូវអារម្មណ៍ជាកិច្ច
- **រូបាទិ អភិមុខីភាវ បច្ចុប្បដ្ឋានា** ជាធម្មជាតិមានមុខតម្រង់ទៅរកអារម្មណ៍ មានរូបជាដើមជាផល
- **ភវង្គ វិច្ឆេទ បទដ្ឋានា** មានការដាច់ខ្សែនៃភវង្គជាហេតុជិត ។

# ធម៌អប់រំចិត្ត

**បិ.៥៧.ទំ.១៦០.សីហាថេរី ស្ដីអំពី សុខចិត្តចងក ព្រោះមិនចង់សឹក**

កាលពីដើមអាត្មាអញត្រូវកាមរាគៈបៀតបៀន ជាអ្នកមានចិត្តរវើរវាយ មិនលុះក្នុងអំណាចនៃភាវនាចិត្ត ព្រោះធ្វើទុកក្នុងចិត្តមិនជាឧបាយនៃប្រាជ្ញា ។ អាត្មាអញលុះត្រូវកិលេសទាំងឡាយរួបរឹតហើយ ជាអ្នកលុះក្នុងអំណាចនៃចិត្ត ដែលប្រកប

*ដោយភាគៈ ក៏មិនបានសេចក្តីស្ងប់ចិត្តឡើយ អាត្មាអញទៅជាស្គមស្ងេកស្ងាំង ស្អាប់សម្បុរប្រព្រឹត្តមកអស់៧ឆ្នាំហើយ អាត្មាអញដល់សេចក្តីទុក្ខក្រៃពេក មិនបានសេចក្តីសុខទាំងយប់ទាំងថ្ងៃ ។ ព្រោះមិនមានសេចក្តីសុខនោះ អាត្មាអញចង់កក្នុងទីនេះប្រសើរជាង ត្រង់ការវិលទៅកាន់ភេទជោកទាបវិញ មិនប្រសើរឡើយ អាត្មាអញបានធ្វើអន្ទាក់យ៉ាងមាំ ចងនឹងមែកឈើ ដាក់អន្ទាក់ត្រង់ក ក៏ស្រាប់តែចិត្តរបស់អាត្មាអញ រួចស្រឡះ ។*

<u>*ពាក្យគួរគិត*</u>

**ល្អ និង អាក្រក់មួយណា ងាយធ្វើជាង** ?

<u>*ពាក្យពិតពិចារណា*</u>

ជាទូទៅមនុស្សយើងចូលចិត្តសម្លឹងឃើញ តែចំពោះផ្នែកអាក្រក់តែប៉ុណ្ណោះ ទៅតាមផ្លូវកាយ វាចា និងចិត្ត។ ម្លោះហើយក៏បានចោទទៅក្នុងបញ្ហានេះថា អំពើអាក្រក់មនុស្សទាំងឡាយងាយធ្វើជាង <u>*ឧទាហរណ៍*</u> ដូចជាសម្លាប់សត្វ លួចទ្រព្យអ្នកដទៃ ។ល។ ប៉ុន្តែបានជាភ្លេចថា មនុស្សល្អទាំងឡាយលំបាកធ្វើណាស់ ចំពោះអំពើអាក្រក់ តែផ្ទុយទៅវិញ អំពើល្អមនុស្សល្អចូលចិត្តណាស់ សប្បាយចិត្តនឹងធ្វើទៀតផង ។

# អហេតុកកិរិយាចិត្តដួងទី២

**២.ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុក-កិរិយាចិត្តំ** មនោវិញ្ញាណធាតុ ដែលជាអហេតុកកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹងឧបេក្ខាវេទនា កើតតាមបញ្ចទ្វារធ្វើវោដ្ឋវនកិច្ច (កិច្ចកំណត់ដឹងនូវអារម្មណ៍ខាងមុខ សន្តីរណកិច្ច គឺកិច្ចពិចារណាអារម្មណ៍)។ បើនៅក្នុងមនោទ្វារ គឺទ្វារចិត្តធ្វើអាវជ្ជនកិច្ច (គឺកិច្ច រំពឹងនឹករកអារម្មណ៍) ជាបឋម ខណៈចិត្តក្នុងមនោទ្វារ។ ចិត្តនេះ ហៅថា មនោទ្វារាវជ្ជនចិត្តក៏បាន ។

**មានចេតសិកប្រកប១១ គឺ**

-អញ្ញសមានាចេតសិក១១ (វៀរ បីតិ ឆន្ទ)

**ចែកជាខន្ធ**

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ៩ | ជាសង្ខារក្ខន្ធ |
| -ចិត្តដួងនេះ | ជាវិញ្ញាណក្ខន្ធ |

**ចែកជាធាតុ**

| | |
|---|---|
| -ចេតសិក ១១ | ជាធម្មធាតុ |
| -ចិត្តដួងនេះ | ជាមនោវិញ្ញាណធាតុ |

**ចែកជាអាយតន**

| | |
|---|---|
| -ចេតសិក១១ | ជាធម្មាយតន |
| -ចិត្តដួងនេះ | ជាមនាយតន |

**ចែកជាសច្ច**

-ចេតសិក ១១ ជាទុក្ខសច្ច

-ចិត្តដួងនេះ ជាទុក្ខសច្ច ។

## មនោទ្វារាវជ្ជនចិត្ត

**មនោទ្វារាវជ្ជន** មកពី (មនោ + ទ្វារ + អាវជ្ជន ) ប្រែថា ពិចារណាអារម្មណ៍ តាមផ្លូវមនោទ្វារ ។

កាលណាអារម្មណ៍ តាមផ្លូវមនោបញ្ចទ្វារ មានចក្ខុទ្វារជាដើមរលត់ហើយ មនោទ្វារាវជ្ជនចិត្ត ក៏ដឹងអារម្មណ៍បន្ត។ មនោទ្វារាវជ្ជនចិត្តអាចដឹងបញ្ញត្តិផ្សេងៗ បានច្រើនណាស់ ដឹងអារម្មណ៍ក៏បាន រូបដទៃៗទៀតក៏បាន ទាំងចិត្តចេតសិក និងនិព្វានក៏បាន ។

កាលណាមនោទ្វារាវជ្ជនចិត្តនេះ ធ្វើកិច្ចស្រេចហើយ ចិត្តដែលកើតតពីនោះ ជាកុសលចិត្តក៏មាន ជាអកុសលចិត្តក៏មាន ជាមហាកិរិយាចិត្តក៏មាន ។ កិច្ចរបស់មនោទ្វារាវជ្ជន គឺពិចារណាអារម្មណ៍ទាំង ៦ និងធ្វើកិច្ចកំណត់អារម្មណ៍ តាមផ្លូវបញ្ចទ្វារ ហៅថា វោដ្ឋវនចិត្ត ។ (ដីកាពន្យល់ថា) ភវង្គចិត្តដែលជា អនន្តរប្បច្ច័យ (ការរលត់ទៅរបស់ចិត្តដួងមុនជាបច្ច័យ ឲ្យកើតចិត្តដួងបន្ទាប់ មិនមានចិត្តដទៃៗខ័ណ្ឌ ហៅថា «អនន្តរប្បច្ច័យ » ) ដល់អាវជ្ជនៈឈ្មោះថា «មនោទ្វារ» ព្រោះសេចក្តីជាច្រកផ្លូវនៃការប្រព្រឹត្តទៅរបស់វិថីចិត្តទាំងឡាយ ។

*ឈ្មោះថា «មនោទ្វារាវជ្ជន» ក៏ព្រោះអត្ថថារមែងនឹកដល់អារម្មណ៍ជាកាន់គន្លង ហើយទាក់ទងជាមួយអារម្មណ៍ ដែលឃើញ បានឮប៉ះខ្ទប់ជាដើម តាមផ្លូវមនោទ្វារនោះ ឬថាញ៉ាំងចិត្តសន្តានឱ្យបង្អោនទៅ ដូចន័យដែលបានពោលហើយនោះឯងបានដល់ចិត្ត គឺអហេតុកមនោវិញ្ញាណធាតុ ចំណែកកិរិយាដែលសហគតដោយឧបេក្ខា ក៏ចិត្តដួងនេះលោកអាចារ្យហៅថា «វោដ្ឋវន» ព្រោះអត្ថថា កំណត់អារម្មណ៍តាមសន្តីរណចិត្ត បានពិចារណាហើយនូវផ្លូវបញ្ចទ្វារ ។*

# ធម៌អប់រំចិត្ត

## *បិ.៥៧.ទំ.១៨៧. ឧប្បលវណ្ណាថេរី. ស្តីអំពី ទោសរបស់កាម*

*យើងទាំងពីរនាក់ គឺមាតានិងកូនស្រី មានប្តីជាមួយគ្នា (ភរិយារួមប្តី) សេចក្តីតក់ស្លុត សេចក្តីព្រឺរោម អស្ចារ្យចំឡែក កើតមានដល់ខ្ញុំនោះ។ (ឧប្បលវណ្ណាថេរីពោលថា) ថ្វីយកាមទាំងឡាយ ជារបស់មិនស្អាត មានក្លិនអាក្រក់ ដូចជាបន្លាច្រើនយ៉ាងដែលនាំយើងទាំងពីរនាក់ គឺមាតា និងកូន ឲ្យជាភរិយាជាមួយគ្នា ។ លុះខ្ញុំឃើញទោសក្នុងកាមទាំងឡាយ ហើយឃើញនេក្ខម្មថា ជារបស់ក្សេម ទើបចេញចាកផ្ទះក្នុងក្រុងរាជគ្រឹះចូលកាន់ផ្នួស ។ ខ្ញុំដឹង*

នូវបុព្វេនិវេស ឯទិព្វចក្ខុនិងចេតោបរិយញ្ញាណ ខ្ញុំជម្រះហើយ ទិព្វសោតជាតុខ្ញុំជម្រះហើយដែរ។ ទាំងឫទ្ធិខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ការអស់ទៅនៃអាសវៈខ្ញុំបានដល់ហើយ អភិញ្ញា ៦ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ពុទ្ធសាសនាខ្ញុំបានធ្វើហើយ ។ ខ្ញុំនិម្មិត្តនូវរថទឹមសេះ៤ ដោយឫទ្ធិ ហើយថ្វាយបង្គំព្រះបាទទាំងគូរនៃព្រះពុទ្ធដ៏មានសិរីជាទីពឹងនៃសត្វលោក ។

(មារមានចិត្តបាបពោលថា) នាងជាស្រីម្នាក់ឯង ចូលមកកាន់ដើមរាំងភ្នំ ដែលនៅចុងមានផ្ការីកស្កុះស្កាយ ហើយឈរនៅទៀបគល់ឈើ បុគ្គលណាមួយជាគម្រប់ពីរ របស់នាងក៏មិនមាននៃស្រីពាល នាងមិនខ្លាចអ្នកលេងទេឬ?

(ឧប្បលវណ្ណាថេរី ពោលថា) បើទុកជាអ្នកលេងទាំងឡាយមួយរយ ឬមួយពាន់ ជាបុគ្គលមានសភាពយ៉ាងនេះ មកជួបជុំគ្នាក៏រោមរបស់យើងមិនព្រឺព្រួច មិនញាប់ញ័រ នៃមារ អ្នកម្នាក់ឯងនឹងធ្វើនូវអ្វីដល់យើងកើត។ យើងនេះនឹងបាត់ទៅ ឬនឹងចូលទៅកាន់ពោះរបស់អ្នកក៏បាន ឬបើទុកជាឈរនៅក្បែរចន្លោះចិញ្ចើមរបស់អ្នក ក៏អ្នកមើលមិនឃើញយើងឈរដែរ ។ យើងជាស្រីដែលស្ទាត់ក្នុងអធិចិត្តឥទ្ធិបាទទាំងឡាយ យើងបានចម្រើនហើយដោយប្រពៃ អភិញ្ញា ៦ យើងបានធ្វើហើយ ។ កាមទាំងឡាយប្រៀបដោយលំពែងនិងឈើស្រួចសម្រាប់ចិញ្ច្រាំនូវខន្ធទាំងឡាយ

អ្នកពោលនូវតម្រេកក្នុងកាមណា ឥឡូវនេះ តម្រេកក្នុងកាមនោះ មិនមែនជាតម្រេករបស់យើងឡើយ ។ សេចក្តីរីករាយក្នុងកាមទាំងអស់យើងបានកំចាត់ចេញហើយ គំនរនៃងងឹត (អវិជ្ជា) យើងបានទំលាយចោលហើយ នែមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ នែមារថោកទាប អ្នកយើងកំចាត់ចេញហើយ ។

## អហេតុកកិរិយាចិត្តដួងទី ៣

**៣-សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ** មនោវិញ្ញាណធាតុ ដែលជាអហេតុកកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនាកើតក្នុងទ្វារ ៦ ធ្វើជវនកិច្ចតែម្យ៉ាង។ ជាចិត្តរបស់ព្រះអរហន្តដែលប្រព្រឹត្តទៅក្នុងការញញឹម ឬហៅ ម្យ៉ាងទៀតថាហសិតុប្បាទចិត្តក៏បាន ។

**មានចេតសិកប្រកប១២ គឺ**

-អញ្ញសមានាចេតសិក១២ (វៀរឆន្ទ)

**ចែកជាខន្ធ**

| | |
|---|---|
| -វេទនាចេតសិក | ជាវេទនាខន្ធ |
| -សញ្ញាចេតសិក | ជាសញ្ញាខន្ធ |
| -ចេតសិក ១០ | ជាសង្ខារកខន្ធ |
| -ចិត្តដួងនេះ | ជាវិញ្ញាណក្ខន្ធ |

### ចែកជាធាតុ

| | |
|---|---|
| -ចេតសិក ១២ | ជាធម្មធាតុ |
| -ចិត្តដួងនេះ | ជាមនោវិញ្ញាណធាតុ |

### ចែកជាអាយតន

| | |
|---|---|
| -ចេតសិក១២ | ជាធម្មាយតន |
| -ចិត្តដួងនេះ | ជាមនាយតន |

### ចែកជាសច្ច

| | |
|---|---|
| -ចេតសិក ១២ | ជាទុក្ខសច្ច |
| -ចិត្តដួងនេះ | ជាទុក្ខសច្ច ។ |

## ហសិតុប្បាទចិត្ត

**ហសិតុប្បាចិត្ត** មកពី (ហសិត +ឧប្បាទ+ចិត្ត) ប្រែមកថា ការកើតឡើងនៃចិត្តញញឹម ។

**ហសិត** ប្រែមកថា រីករាយ ញញឹមញញែម

**ឧប្បាទ** ប្រែមកថា ការកើតឡើង

ហសិតុប្បាទចិត្តនេះ ជាចិត្តរបស់ព្រះអរហន្តកើតព្រម នឹងសោមនស្សវេទនា ជាចិត្តដែលធ្វើរូបឲ្យញញឹមញញែម ។ ដូចរឿងព្រះមហាមោគ្គល្លានឃើញប្រេត ដែលកំពុងទទួលទុក្ខវេទនា ការឃើញនោះ ឃើញបានដោយកិរិយាអភិញ្ញាចិត្ត ដែល

ប្រព្រឹត្តទៅព្រមនឹងការពិចារណាថា សភាពបែបនេះលែងកើតមានដល់អាត្មាអញទៀតហើយ ហសិតុប្បាទចិត្តក៏កើតឡើង ។

ក្នុង (គម្ពីរសុពោធាលង្ការ) បានពោលពីការសើចញញឹមញញែមមាន៦ យ៉ាងគឺ:

**១.សិត** ញញឹមមិនឃើញធ្មេញ ជាការញញឹមនៃព្រះពុទ្ធជាម្ចាស់ ។

**២.ហសិត** ញញឹមល្មមឃើញធ្មេញ ជាការញញឹមនៃព្រះអរហន្តនៃព្រះអនាគាមី នៃព្រះសកទាគមី នៃព្រះសោតាបន្ន និងនៃបុថុជ្ជន្ន ។ ការញញឹមនេះក្រៅពីព្រះអរហន្តហើយ រមែងប្រកបដោយហេតុបុណ្យ ឬ ដោយហេតុបាប ។

**៣.វិហសិត** សើចឮសំឡេងស្រាលៗ កើតនឹងចិត្តរបស់បុថុជ្ជន និងព្រះអរិយ ៣ពួក (វៀរព្រះ អរហន្ត) ។

**៤.អតិហសិត** សើចឮសំលេងខ្លាំង កើតចំពោះបុថុជ្ជនព្រះសោតាបន្ន ព្រះសកទាគាមី ។

**៥.ឧបហសិត** សើចរហូតដល់កាយញ័រ ។

**៦.អបហសិត** សើចរហូតដល់ហូរទឹកភ្នែក ជាការសើចរបស់បុថុជ្ជន ។

**សិតៈ**និង**ហសិតៈ** ជាការញញឹមរបស់ព្រះអរហន្តជាចិត្តញញឹមដោយមិនប្រកាន់មាំក្នុងអារម្មណ៍ ដូចជាការសើចរបស់បុគ្គលដទៃៗទៀតឡើយ ចិត្តនេះទើបមានកម្លាំងខ្សោយជាចិត្តពិសេសហៅថាហសិតុប្បាទចិត្ត ។ កាលដែលចិត្តមានកម្លាំងតិចតួច នេះឯងទើបជាអហេតុកចិត្ត ចំណែកចិត្តសើចដទៃៗជាសហេតុកចិត្ត។

(ដីកាពន្យល់ថា) ឈ្មោះថា «**ហសិតុប្បាទ**» ព្រោះអត្ថថាញុំាងការញញឹមញញែមឲ្យកើតឡើង បានដល់ចិត្តគឺអហេតុក-មនោវិញ្ញាណធាតុជាកិរិយា ដែលជាហេតុត្រឹមតែអាការៈរីករាយក្នុងអារម្មណ៍ទាំងឡាយ ដែលមិនគ្រោតគ្រាតនៃព្រះអរហន្ត ។

(យោជនាពន្យល់ថា) ពាក្យថា «ក្នុងអារម្មណ៍ទាំងឡាយដែលមិនគ្រោតគ្រាត» បានដល់ក្នុងអារម្មណ៍ទាំងឡាយ ដែលប្រព្រឹត្តទៅស្ថានទី ដែលសមគួរដល់ការប្រារព្ធការព្យាយាមជាដើម ។

## លក្ខណាទិចតុករបស់ហសិតុប្បាទចិត្ត

- **ឆឡារម្មណា វិជានន លក្ខណា** មានការដឹងច្បាស់នូវអារម្មណ៍ ៦ជាលក្ខណៈ

- **កិច្ចវសេន អរហតំ អនុឡាលសុ វត្ថុសុ ហសិតុប្បាទនរសា** មានការញញឹមញញែមក្នុងវត្ថុទាំងឡាយ ដែល

មិនជាល្អអ្វីទេ កើតមានដល់ចំពោះព្រះអរហន្តទាំងឡាយ ដោយអំណាចនៃកិច្ច ជាកិច្ច

- **ឥច្ឆាភាវ បច្ចុប្បដ្ឋានា** មានសភាពជាយ៉ាងនោះឯង គឺហសិតុប្បាទជាផល

- **ឯកន្តតោ ហទយវត្ថុ បទដ្ឋានា** មានហទយវត្ថុប៉ុណ្ណោះ ជាហេតុជិត។

# ធម៌អប់រំចិត្ត

**បិ.៥៧.ទំ.១៩១.អម្ពបាលីថេរី ស្ដីអំ ពីពាក្យពិតមិនប្រែប្រួល**

កាលពីដើមសក់របស់ខ្ញុំមានចុងង មានពណ៌ខ្មៅប្រាកដស្មើ ដោយស្លាបនៃកន្ធង់ ឥឡូវនេះសក់ទាំងឡាយនោះ ប្រាកដស្មើ ដោយសម្បកធ្មៃ និងសម្បកក្រចៅ ព្រោះតែជរាព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល។

កាលពីដើម សំណុំសក់របស់ខ្ញុំពេញដោយផ្កា ហាក់ដូចជាប្រអប់ដាក់គ្រឿងក្រអូបដែលគេអប់ (ឥឡូវនេះ) សំណុំសក់នោះមានក្លិនដូចជាក្លិននៃរោមទន្សាយ ព្រោះតែជរាព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល។

កាលពីដើម សក់របស់ខ្ញុំវិចិត្រដោយក្រាសនឹងស្នៀតសក់ល្អលើសលប់ ដូចជាព្រៃឫស្សីដុះស្អាប់ល្អ ឥឡូវនេះសក់នោះ

ល្បោះល្បើលក្នុងសីសប្រទេសនោះ ព្រោះតែជរាព្រះពុទ្ធដីការបស់ ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម សក់របស់ខ្ញុំល្អិត មានក្លិនក្រអូបស្អិតស្អាងដោយក្រាសមាស ប្រដាប់ដោយផ្គងទាំងឡាយ ដ៏ល្អត្រកាល ឥឡូវនេះ សក់នោះថ្លែកព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម ចិញ្ចើមទាំងឡាយរបស់ខ្ញុំស្អាតល្អ ដូចជាគំនូសដែលជាងរចនាល្អ ឥឡូវនេះចិញ្ចើមទាំងនោះយុរយារ ដោយអាការៈជ្រីវជ្រួញ ព្រោះតែជរាព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលពាក្យពិតមិនប្រែប្រួល ។

កាលពីដើម ភ្នែកទាំងឡាយមានសម្បុរថ្លាខៀវស្រងាត់រុងរឿងល្អក្រឡង់ ដូចជាកែវមណី ឥឡូវនេះ ភ្នែកទាំងនោះ ត្រូវជរាញាំញីក៏បែរជាមិនល្អ ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល។

ច្រមុះរបស់ខ្ញុំប្រាកដស្មើដោយជម្បារមាស ដែលគេមូរដ៏ល្អល្អក្នុងកាលនៃខ្លួននៅក្រមុំ ឥឡូវនេះច្រមុះនោះ ហាក់ដូចជាទ្រុឌទ្រោមព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម ស្បែកត្រចៀកទាំងឡាយរបស់ខ្ញុំ ហាក់ដូចជាជម្ពូរមាស ដែលជាងធ្វើល្អហើយ ដែលសម្រេចហើយដោយប្រពៃ ឥឡូវនេះ ស្បែកត្រចៀកទាំងនោះយុរយារ ដោយអាការៈជ្រីវជ្រួញព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម ធ្មេញទាំងឡាយរបស់ខ្ញុំល្អណាស់ ប្រាជកស្មើដោយពណ៌នៃផ្កាត្រនៀងក្រពុំ ឥឡូវនេះធ្មេញទាំងនោះ បាក់មានពណ៌លឿងដូចជាស្រូវដំណើបព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម សម្ដីដែលខ្ញុំនិយាយពីរោះ ដូចជាសំដីមេតាវៅដែលហើរទៅកាន់ព្រៃស្រោងក្នុងព្រៃ ឥឡូវនេះ សម្ដីនោះស្អកស្អាព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម ករបស់ខ្ញុំល្អ ដូចជាស័ង្ខមាស ដែលជាងខាត់ហើយដោយល្អ ឥឡូវនេះកនោះបាក់ឱនព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម ដើមដៃរបស់ខ្ញុំទាំងពីរល្អ ដូចជាសសរខឿនដែលជាងលញ់ហើយ ឥឡូវនេះដើមដៃទាំងនោះ ដូចជាស័ង្ខបែក

ហើយព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល។

កាលពីដើម ដៃទាំងឡាយរបស់ខ្ញុំមានចិញ្ចៀនល្អប្រដាប់ដោយមាសសមរម្យល្អ ឥឡូវនេះ ដៃទាំងនោះដូចជាមើមដំឡូងយារព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល។

កាលពីដើម ដោះទាំងពីររបស់ខ្ញុំពេញលេញមូលក្បំកៀកគ្នាមានសណ្ឋានដ៏ត្រង់ល្អណាស់ ឥឡូវនេះ ដោះទាំងនោះមិនមានទឹក ជ្រាយបាក់សំយុងចុះដូចជាបំពង់ទឹក ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោល នូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម កាយរបស់ខ្ញុំល្អស្រល់ ដូចជាផែនក្តារមាសដែលគេខាត់ហើយដោយប្រពៃ ឥឡូវនេះ កាយនោះប្រែប្រួលដោយអាការៈជ្រីវជ្រួញដ៏ល្អិត ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម ភ្លៅទាំងពីររបស់ខ្ញុំល្អល្អះ ដូចជាប្រមោយនៃដំរីដ៏ប្រសើរ ឥឡូវនេះ ភ្លៅទាំងនោះដូចជាថ្នាំងឬស្សីព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម ស្មងទាំងឡាយរបស់ខ្ញុំ ប្រដាប់ដោយស្រោមជាវិការៈនៃមាស ដែលគេប៉ាក់ជិតស្និតល្អណាស់ ឥឡូវនេះ ស្មង

ទាំងនោះដូចជាដើមល្វ ព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

កាលពីដើម ជើងទាំងពីររបស់ខ្ញុំល្អ ដូចជាទ្រនាប់ជើងដែលគេញាត់ ហើយដោយប៉ុយរកា ឥឡូវនេះ ជើងទាំងនោះប្រេះបែកជ្រីវជ្រួញ ព្រោះតែជរា ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោលនូវពាក្យពិតមិនប្រែប្រួល ។

គ្រោងកាយ មានសភាពដូច្នេះនេះ គ្រាំគ្រាជាលំនៅនៃសេចក្ដីទុក្ខច្រើនប្រការ គ្រោងកាយនោះ ដូចជាផ្ទះចាស់ដែលមានគ្រឿងបូកលាបជ្រុះចុះ ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពោល នូវពាក្យពិតមិនប្រែប្រួល ។

<u>ពាក្យគួរដឹង</u>

**អំពើល្អ មនុស្សល្អធ្វើបានដោយងាយ**

## ឧប្បត្តិហេតុនៃអហេតុកចិត្ត

*ឧប្បត្តិហេតុ គឺហេតុដែលកើតឡើងនៃ អហេតុចិត្ត ១៨ ដួង ។ ក្នុងអដ្ឋកថា ឈ្មោះអដ្ឋសាលនីសម្តែងទុកថា ៖*

**ហេតុឲ្យកើតចក្ខុវិញ្ញាណ២ដួងមាន ៤គឺ**

**១.អសម្ភិន្នត្តា ចក្ខុស្ស** *ព្រោះចក្ខុបសាទមិនទាន់បែកធ្លាយ*

**២.អាបាថគតត្តា រូបានំ** *ព្រោះរូបមកកាន់គន្លង*

**៣.អាលោក សន្និស្សិតំ** *អាស្រ័យដោយពន្លឺ*

**៤. មនសិការ ហេតុកំ** *មានមនសិការជាហេតុ ។*

*ចំពោះហេតុបច្ច័យទាំង ៤ នោះ ចក្ខុនៃអ្នកស្លាប់គឺចក្ខុនៃអ្នកមានជីវិតដែលរលត់ក្តី ឬ ចក្ខុដែលត្រូវទឹកប្រម៉ាត់ ឬ ដែលត្រូវស្លេស្ម ឬ លោហិតបាំងបិទក្តី ដែលមិនអាចជាបច្ច័យដល់ចក្ខុវិញ្ញាណ ឈ្មោះថាបែកធ្លាយហើយ ប៉ុន្តែបើនៅជាបច្ច័យបាន ឈ្មោះថា មិនទាន់បែកធ្លាយ ។*

*សូម្បីចក្ខុបសាទ មិនទាន់បែកធ្លាយក៏ដោយ ប៉ុន្តែបើរូបារម្មណ៍ (វណ្ណរូប ពណ៌) នៅមិនទាន់មកកាន់គន្លង នឹងចក្ខុបសាទទេ ចក្ខុវិញ្ញាណក៏កើតឡើងមិនបាន ។*

*ប្រសិនបើរូបារម្មណ៍នោះ មកកាន់គន្លងហើយ ប៉ុន្តែបច្ច័យដែលអាស្រ័យ គឺពន្លឺមិនមានចក្ខុវិញ្ញាណ ក៏កើតឡើងមិនបាន ។*

ប្រសិនបើពន្លឺដែលជាបច្ច័យនោះមានប៉ុន្តែកិរិយាមនោធាតុ មិនញ៉ាំងភវង្គឱ្យផ្លាស់ប្តូរទៅទេ ចក្ខុវិញ្ញាណក៏កើតឡើងមិនបាន។

កាលណាកិរិយាមនោធាតុ ញ៉ាំងភវង្គឲ្យផ្លាស់ប្តូរទៅបានចក្ខុ-វិញ្ញាណ ទើបឡើងធ្វើទស្សនកិច្ច (កិច្ចឃើញរូប) ។ ចក្ខុវិញ្ញាណ កាលបើកើតឡើង រមែងកើតឡើងព្រមដោយសម្បយុត្តធម៌ទាំង ឡាយ ដោយពិតដូច្នេះហើយទើបពោលថា ចក្ខុវិញ្ញាណកើត ព្រោះអាស្រ័យបច្ច័យ ៤ ប៉ុណ្ណោះ ។

# ធម៌អប់រំចិត្ត

បិ.៥២.ទំ.២៨. គាថាធម្មបទ ស្តីអំពី ការធ្វើចិត្តឱ្យត្រង់

**ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ**
**ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ ។**
**វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ**
**បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។**

អ្នកប្រាជ្ញតែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបាន ដោយកម្រហាមឃាត់បានដោយលំបាក ឱ្យជាចិត្តត្រង់បាន ដូច អ្នកធ្វើព្រួញពត់ព្រួញឱ្យត្រង់ ។ ចិត្តនេះ ដែលបុគ្គលលើកឡើង ចាកអាល័យគឺកាមគុណ ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បី លះបង់នូវវដ្តជាទីនៅនៃមារ រមែងញាប់ញ័រដូចត្រី ដែលឡើង ចាកទីនៅគឺទឹក បោះទៅលើគោក ដូច្នោះឯង ។

ព្រះសម្ពុទ្ធសម្តែង មានប្រារព្ធចំពោះមេឃិយត្ថេរ

**លក្ខណាទិចតុករបស់ចក្ខុវិញ្ញាណ**

**-ចក្ខុសន្និស្សិត រូបាវិជាននលក្ខណំ** *មានការដឹងរូបារម្មណ៍បានអាស្រ័យចក្ខុបសាទជា លក្ខណៈ*

**-រូបមត្តារម្មណ រសំ** *មានការដឹងអារម្មណ៍ត្រឹមតែរូបារម្មណ៍ ជាកិច្ច*

**-រូបាភិមុខភាវ បច្ចុប្បដ្ឋានំ** *មានការសំដៅមុខចំពោះរូបារម្មណ៍ ជាផល*

**-រូបារម្មណាយ កិរិយាមនោធាតុយា អបគមន បទដ្ឋានំ** *មានការមិនប្រាសទៅ នៃកិរិយាមនោធាតុ ជាហេតុជិត ។*

# ធម៌អប់រំចិត្ត

បិ.៥២.ទំ.២៨. គាថាធម្មបទ ស្តីអំពី ចិត្តជាធម្មជាតិស្រាល

**ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ**
**ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។**

*ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតិស្រាលរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នាក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឱ្យសម្រេច ព្រោះថាចិត្ត ដែលហ្វឹកហ្វឺនអប់រំបានហើយរមែងនាំមកនូវសេចក្តីសុខ ។*

ព្រះសម្ពុទ្ធសម្ដែងប្រាប់ពួចំពោះភិក្ខុមួយរូប

**ហេតុឱ្យកើតសោតវិញ្ញាណ២ដួចមាន ៤គឺ**

**១.អសម្ភិន្នត្តា សោតស្ស** *ដោយសោតនោះនៅមិនទាន់បែកធ្លាយ*

**២.អាបាថគតត្តា សទ្ទានំ** *ដោយសំឡេងទាំងឡាយមកកាន់គន្លង*

**៣.អាកាស សន្និស្សិតំ** *អាស្រ័យអាកាស (លំហ)*

**៤.មនសិការ ហេតុកំ** *មានមនសិការជាហេតុ ។*

*បណ្ដាបច្ច័យទាំង ៤ នោះ ពាក្យថា អាស្រ័យអាកាស គឺសោតវិញ្ញាណនោះ បានអាស្រ័យនូវអាកាសទើបកើតឡើង វៀរនូវអាកាសហើយកើតមិនបាន ព្រោះកាលណាបុគ្គលបិទរន្ធត្រចៀកជិតសោតវិញ្ញាណ ក៏មិនអាចប្រព្រឹត្តទៅបាន ។ ពាក្យដែលក្រៅពីនេះ គប្បីជ្រាបដោយន័យ ដែលបានពោលហើយក្នុងរឿងចក្ខុវិញ្ញាណ ។*

# ធម៌អប់រំចិត្ត

បិ.៥២.ទំ.២៩. គាថាធម្មបទ ស្ដីអំពី ចិត្តជាធម្មជាតិល្អិត

**សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**
**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។**

*អ្នកមានប្រាជ្ញាគួររក្សាចិត្ត ដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នាក្នុងអារម្មណ៍ណាមួយ ព្រោះថាចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។*

ព្រះសម្ពុទ្ធសម្ដែងប្រារព្ធចំពោះឧកណ្ឋិតភិក្ខុ

## លក្ខណាទិចតុក្ករបស់សោតវិញ្ញាណ

-**សោត សន្និស្សិត សទ្ទវិជានន លក្ខណំ** *មានការដឹងនូវសទ្ទារម្មណ៍បានអាស្រ័យសោតបសាទជាលក្ខណៈ*

-**សទ្ទមត្តារម្មណ រសំ** *មានការដឹងត្រឹមតែសទ្ទារម្មណ៍ជាកិច្ច*

-**សទ្ទាភិមុខភាវ បច្ចុប្បដ្ឋានំ** *មានការសំដៅមុខចំពោះសទ្ទារម្មណ៍ ជាផល*

-**សទ្ទារម្មណាយ កិរិយាមនោធាតុយា អបគមន បទដ្ឋានំ** *មានការមិនប្រាសទៅនៃកិរិយាមនោធាតុ ជាហេតុជិត។*

## ធម៌អប់រំចិត្ត

បិ.៥២.ទំ.២៩ គាថាធម្មបទ.ស្ដីពី ចិត្តត្រាច់ទៅតែឯង

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**

**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា**

*អ្នកទាំងឡាយ នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯងមិនមានសរីរៈ មានគុហាគឺមហាភូតរូប ៤ ជាទីអាស្រ័យ នៅអ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។*

ព្រះសម្មាសម្ពុទ្ធសម្តែងប្រារព្ធចំពោះភាគិនេយ្យសង្ឃរក្ខិតត្ថេរ

## ហេតុឱ្យកើតឃានវិញ្ញាណ ២៨ួប មាន ៤ គឺ

**១.អសម្ភិន្នត្តា ឃានស្ស** *ដោយឃានបសាទនូវមិនទាន់បែកធ្លាយ*

**២.អាបាថគតត្តា គន្ធានំ** *ដោយក្លិនទាំងឡាយមកកាន់គន្លង*

**៣.វាយោ សន្និស្សិតំ** *អាស្រ័យវាយោ (ខ្យល់)*

**៤.មនសិការ ហេតុកំ** *មានមនសិការជាហេតុ ។*

*បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថាអាស្រ័យវាយោ គឺកាលណាបើវាយោផាត់នូវក្លិនទាំងឡាយ ចូលមកកាន់រន្ធច្រមុះនោះ ហើយឃានវិញ្ញាណទើបកើតបាន ។ ប្រសិនបើ វាយោគឺខ្យល់មិនមានទេ ឃានវិញ្ញាណក៏កើតមិនបាន ។*

# ធម៌អប់រំចិត្ត

បិ.៥២.ទំ.២៩. គាថាធម្មបទ ស្តីអំពីចិត្តមិនទទឹកដោយកិលេស

**អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ**
**បរិប្លវបសាទស្ស បញ្ញា ន បរិបូរតិ**

**អនវស្សុតចិត្តស្ស អនន្វាហតចេតសោ**
**បុញ្ញបាបប្បហីនស្ស នត្ថិ ជាគរតោ ភយំ ។**

*ប្រាជ្ញារមែងមិនបរិបូរណ៍ដល់បុគ្គល ដែលមានចិត្តមិនខ្ជាប់ខ្ជួនមិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្ដីជ្រះថ្លាអណ្ដែតទៅ ។ ភ័យរមែងមិនមានដល់បុគ្គល អ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសៈខ្ទាំងខ្ទប់ មិនបានមានបុណ្យ និងបាបលះចោល ហើយភ្ញាក់រំលឹកជានិច្ច ។*

ព្រះសម្ពុទ្ធសម្ដែងប្រារព្ធចំពោះចិត្តហត្ថត្ថេរ

## លក្ខណាទិចតុករបស់ឃានវិញ្ញាណ

-**ឃានសន្និស្សិត គន្ធវិជានន លក្ខណំ** *មានការដឹងនូវគន្ធារម្មណ៍បានអាស្រ័យឃានបសាទ ជាលក្ខណៈ*

-**គន្ធមត្តារម្មណ រសំ** *មានការដឹងត្រឹមតែក្លិន ជាកិច្ច*

-**គន្ធាភិមុខភាវ បច្ចុប្បដ្ឋានំ** *មានការសំដៅមុខចំពោះគន្ធារម្មណ៍ ជាផល*

-**គន្ធារម្មណាយ កិរិយាមនោធាតុយា អបគមន បទដ្ឋានំ** *មានការមិនប្រាសទៅ នៃកិរិយាមនោធាតុ ជាហេតុជិត ។*

# ធម៌អប់រំចិត្ត

បិ.៥២.ទំ.២៩.គាថាធម្មបទ ស្តីអំពីកាយឧបមាដូចឆ្នាំងដី

**កុម្ភូបមំ កាយមិមំ វិទិត្វា នគរូបមំ ចិត្តមិទំ ឋបេត្វា**
**យោធេថ មារំ បញ្ញាវុធេន ជិតញ្ច រក្ខេ អនិវេសនោ សិយា ។**

*បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំងដីគប្បីបិទនូវចិត្តនេះ ឱ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនូវមារដោយអាវុធគឺបញ្ញា គប្បីរក្សាទុកនូវធម៌ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកតំអក់នៅក្នុងធម៌នោះឡើយ ។*

ព្រះសម្ពុទ្ធសម្តែងប្រារព្ធចំពោះ អារទ្ធវិបស្សកភិក្ខុ

## ហេតុឱ្យកើតជីវ្ហាវិញ្ញាណ ២ ដូចមាន៤គឺ

**១.អសម្ភិន្នត្តា ជីវ្ហាយ** *ដោយជីវ្ហាបសាទនូវមិនទាន់បែកធ្លាយ*

**២.អាបាថគតត្តា រសានំ** *ដោយរសទាំងឡាយមកកាន់គន្លង*

**៣.អាបោ សន្និស្សិតំ** *អាស្រ័យអាបោ* (គឺទឹក)

**៤មនសិការ ហេតុកំ** *មានមនសិការជាហេតុ ។*

*បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថាអាស្រ័យអាបោបានដល់អាបោគឺទឹកធ្វើឱ្យសើមជីវ្ហាវិញ្ញាណ ទើបកើតឡើងបាន រៀរ*

*អាបោហើយក៏មិនអាចកើតឡើង ព្រោះថាកាលណា បើបុគ្គល អណ្តាតស្ងួត សូម្បីដាក់ខាទនីយៈ ត្រង់អណ្តាតនោះក៏ដោយ ជីវ្ហាវិញ្ញាណ ក៏កើតឡើងមិនបាន ។*

# ធម៌អប់រំចិត្ត

បិ.៥២.ទំ.៣០.គាថាធម្មបទ ស្តីអំពី កាយដូចអង្កត់ឱស

**អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ**

**ឆុឌ្ឌោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។**

*ឱហ្ន៎ ! មិនយូរប៉ុន្មានឡើយ កាយនេះមានវិញ្ញាណទៅប្រាស ហើយគេយកទៅចោលផុតហើយ មុខជានឹងដេកស្តូកស្តឹងលើ ផែនដី ដូចជាអង្កត់ឱស រកប្រយោជន៍គ្មាន ។*

ព្រះសម្ពុទ្ធសម្តែងប្រារព្ធចំពោះបូតិគតតិស្សត្ថេរ

## លក្ខណាទិចតុក្ករបស់ជីវ្ហាវិញ្ញាណ

**-ជីវ្ហាសន្និស្សិត រសវិជានន លក្ខណំ** *មានការដឹងរស បានអាស្រ័យជីវ្ហាបសាទ ជាលក្ខណៈ*

**-រសមត្តារម្មណ រសំ** *មានការដឹងត្រឹមតែរស ជាកិច្ច*

**-រសាភិមុខភាវ បច្ចុប្បដ្ឋានំ** *មានការសម្លឹងទៅមុខរសារម្មណ៍ ជាផល*

**-រសារម្មណាយ កិរិយាមនោធាតុយា អបគមន បទដ្ឋានំ** *មានការមិនប្រាសទៅនៃកិរិយាមនោធាតុ ជាហេតុជិត ។*

## ធម៌អប់រំចិត្ត

បិ.៥២.ទំ.៣០. គាថាធម្មបទ ស្តីអំពី ការតម្កល់ចិត្តខុស

**ទិសោ ទិសំ យន្តំ កយិរា  វេរី វា បន វេរិនំ**

**មិច្ឆាបណិហិតំ ចិត្តំ  បាបិយោ នំ តតោ ករេ ។**

*ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយដល់គ្នាចិត្តដែលបុគ្គលតាំងទុកខុសហើយរមែងធ្វើបុគ្គលនោះឱ្យអាក្រក់ក្រៃលែងជាងសេចក្តីវិនាសនោះទៅទៀត ។*

ព្រះសម្ពុទ្ធសម្តែងប្រារព្ធចំពោះនាយនន្ទគោបាល

## ហេតុឱ្យកើតកាយវិញ្ញាណ ២ ដួង មាន ៤ គឺ

**១.អសម្ភិន្នត្តា កាយស្ស** *ដោយកាយបសាទនូវមិនទាន់បែកធ្លាយ*

**២.អាបាថគតត្តា ផោដ្ឋព្វានំ** *ដោយផោដ្ឋព្វៈមកកាន់គន្លង*

**៣.បឋវី សន្និស្សិតំ** *អាស្រ័យបឋវី (គឺដី)*

**៤.មនសិការ ហេតុកំ** *មានមនសិការ ជាហេតុ ។*

*បណ្តាបច្ច័យទាំង៤ នោះ ពាក្យថាអាស្រ័យបឋវី បានដល់បឋវីដែលផ្តុំគ្នាគឺកាយបសាទនោះឯងជាបច្ច័យ ទើបកាយវិញ្ញាណកើតឡើង វៀរនូវកាយបសាទ ហើយកាយវិញ្ញាណក៏មិនអាចកើតឡើងបានដែរ ព្រោះមហាភូតរូប ជាអារម្មណ៍ខាងក្រៅប៉ះខ្ទប់មហាភូតរូបទាំងឡាយ ដែលមានកាយបសាទជាបច្ច័យ ។*

## ធម៌អប់រំចិត្ត

បិ.៥២.ទំ.៣០.គាថាធម្មបទ ស្តីអំពី ការតំកល់ចិត្តត្រូវ

**ន តំ មាតា បិតា កយិរា អញ្ញេ វាបិច ញាតកា**
**សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ។**

*មាតាបិតាមិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិមិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្តដែលបុគ្គលតាំងទុកត្រូវហើយរមែងធ្វើបុគ្គលនោះឱ្យប្រសើរជាងហេតុនោះបាន។*

ព្រះសម្ពុទ្ធសម្តែងប្រារព្ធចំពោះសោរេយ្យត្ថេរ

## លក្ខណាទិចតុក្ករបស់កាយវិញ្ញាណ

**-កាយសន្និស្សិត ផោដ្ឋព្វ វិជានន លក្ខណំ** មានការដឹងនូវផោដ្ឋព្វៈ អាស្រ័យកាយបសាទ ជាលក្ខណៈ

**-ផោដ្ឋព្វមត្តារម្មណ រសំ** មានការដឹងត្រឹមតែផោដ្ឋព្វៈ ជាកិច្ច

**-ផោដ្ឋព្វារម្មណាយ កិរិយាមនោធាតុយា អបគមន បទដ្ឋានំ** មានការមិនប្រាសទៅនៃកិរិយាមនោធាតុ ជាហេតុជិត ។

## ធម៌អប់រំចិត្ត

បិ.៥៣.ទំ.៨៩. ឥតិវុត្តក ស្ដីអំពី កូន៣យ៉ាង

ខ្ញុំបានស្ដាប់មកថា ពាក្យនុ៎ះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយព្រះអរហន្តសម្ដែងហើយ ។ ម្នាលភិក្ខុទាំងឡាយបុត្ត ៣ យ៉ាងនេះរមែងមានប្រាកដក្នុងលោក ។ បុត្ត៣យ៉ាងតើអ្វីខ្លះ ? គឺអតិជាតបុត្ត១ អនុជាតបុត្ត១ អវជាតបុត្ត១ ។ ម្នាលភិក្ខុទាំងឡាយ អតិជាតបុត្ត តើដូចម្ដេច ?

ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្តក្នុងលោកនេះ ជាអ្នកមិនដល់ព្រះពុទ្ធជាទីរលឹក មិនដល់ព្រះធម៌ជាទីរលឹក មិនដល់ព្រះសង្ឃជាទីរលឹក មិនវៀរចាកបាណាតិបាត មិនវៀរចាកអទិន្នាទាន មិនវៀរចាកកាមេសុមិច្ឆាចារ មិនវៀរចាកមុសាវាទ មិនវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាបុគ្គលទ្រុស្តសីល ជា

អ្នកមានធម៌ដ៏លាមក ទើបឯកូនរបស់មាតាបិតាទាំងនោះ ជាអ្នកដល់ព្រះពុទ្ធជាទីរលឹក ដល់ព្រះធម៌ជាទីរលឹក ដល់ព្រះសង្ឃជាទីរលឹក វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ម្នាលភិក្ខុទាំងឡាយកូនយ៉ាងនេះឯង ឈ្មោះថាអតិជាតបុត្ត ។

ម្នាលភិក្ខុទាំងឡាយ អនុជាតបុត្ត តើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្តក្នុងលោកនេះ ដល់ព្រះពុទ្ធ ជាទីរលឹក ដល់ព្រះធម៌ជាទីរលឹក ដល់ព្រះសង្ឃជាទីរលឹក វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល ជាអ្នកមានកល្យាណធម៌ ទើបឯកូនរបស់មាតាបិតាទាំងនោះ ដល់ព្រះពុទ្ធជាទីរលឹក ដល់ព្រះធម៌ជាទីរលឹក ដល់ព្រះសង្ឃជាទីរលឹក វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ដែរ ម្នាលភិក្ខុទាំងឡាយកូនយ៉ាងនេះឯង ឈ្មោះ ថាអនុជាតបុត្ត ។ ម្នាលភិក្ខុទាំងឡាយ អវជាតបុត្តតើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយមាតាបិតារបស់បុត្តក្នុងលោកនេះ ដល់ព្រះពុទ្ធជាទីរលឹក ដល់ព្រះធម៌ជាទីរលឹក ដល់ព្រះសង្ឃជាទីរលឹក វៀរបាណាតិបាត វៀរអទិន្នាទាន វៀរ

កាមេសុមិច្ឆាចារ វៀរមុសាវាទ វៀរសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ទើបកូនរបស់មាតាបិតាទាំងនោះ មិនដល់ព្រះពុទ្ធជាទីរលឹក មិនដល់ព្រះធម៌ជាទីរលឹក មិនដល់ព្រះសង្ឃជាទីរលឹក មិនវៀរចាកបាណាតិបាត មិនវៀរចាកអទិន្នាទាន មិនវៀរចាកកាមេសុមិច្ឆាចារ មិនវៀរចាកមុសាវាទ មិនវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាបុគ្គលទ្រុស្តសីល ជាអ្នកមានធម៌ដ៏លាមក ម្នាលភិក្ខុទាំងឡាយកូនយ៉ាងនេះឯង ឈ្មោះថាអវជាតបុត្ត ។ ម្នាលភិក្ខុទាំងឡាយកូន៣នេះរមែងមានប្រាកដក្នុងលោក ។ លុះព្រះមានព្រះភាគ ទ្រង់សម្ដែងសេចក្ដីនុ៎ះហើយ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា ៖

**អតិជាតំ អនុជាតំ បុត្តមិច្ឆន្តិ បណ្ឌិតា**
**អវជាតំ ន ឥច្ឆន្តិ យោ ហោតិ កុលគន្ធនោ ។**
**ឯតេខោ បុត្តា លោកស្មឹ យេ ច ភវន្តិ ឧបាសកា**
**សទ្ធាសីលេន សម្បន្នា វទញ្ញូ វីតមច្ឆរា**
**ចន្ទោ អព្ភឃនា មុត្តោ បរិសាសុ វិរោចរេតិ ។**

បណ្ឌិតទាំងឡាយតែងប្រាថ្នាអតិជាតបុត្ត និងអនុជាតបុត្ត មិនប្រាថ្នាអវជាតបុត្ត ដែលជាកូនផ្ដាច់បង់ត្រកូលឡើយ ។ កូនទាំងនេះឯងតែងមានក្នុងលោក ម៉្យាងទៀតកូនទាំងឡាយណាជាឧបាសក កូនទាំងនោះឈ្មោះថាជាអ្នកបរិបូរណ៍ដោយសទ្ធា និងសីលជាអ្នកដឹងពាក្យពេចន៍ ជាអ្នកប្រាសចាកសេចក្ដីកំណាញ់

រមែងរុងរឿងក្នុងពួកបរិស័ទ ដូចជាព្រះច័ន្ទដែលផុតស្រឡះ ហើយចាកដុំនៃពពកដូច្នោះ ។

## ហេតុឱ្យកើតមនោធាតុ ៣ មាន ៤ គឺ

**១.បញ្ចទ្វារ** មានបសាទ៥ គឺចក្ខុ សោត ឃាន ជីវ្ហា កាយ

**២.បញ្ចារម្មណ** មានអារម្មណ៍ គឺរូបជាដើមមកកាន់គន្លង

**៣.ហទយវត្ថុ** អាស្រ័យហទយវត្ថុរូប (បញ្ចវាការភព)

**៤.មនសិការហេតុកំ** មានមនសិការ ជាហេតុ ។

មនោធាតុ ៣ ដួង គឺបញ្ចទ្វារាវជ្ជនចិត្ត ១ ដួង សម្បដិច្ឆន្នចិត្ត ២ ដួង ។ ចិត្ត៣ដួងនេះ ហៅថាមនោធាតុ ប្រែថាធាតុដឹង ។ មនោវិញ្ញាណធាតុ ជាចិត្តដែលមានអំណាច អាចដឹងអារម្មណ៍បានច្រើនជាងបញ្ចវិញ្ញាណ និងមនោធាតុ ។ ក្នុងអហេតុកចិត្តនេះ មានមនោវិញ្ញាណធាតុ ៥ ដួង គឺមនោទ្វារាវជ្ជនចិត្ត ១ ដួង សន្តីរណចិត្ត ៣ ដួង និងហសិតុប្បាទចិត្ត ១ ដួង ។ តាមសេចក្ដីពិតចិត្តទាំងអស់ ៨៩ ដួង ឬ ១២១ ដួង នោះ វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង និងមនោធាតុ ៣ ដួង ចេញហើយនៅសល់ចិត្ត ៧៦ ឬ ១០៨ ដួងទាំងអស់នេះ ជាមនោវិញ្ញាណធាតុ ។

# ធម៌អប់រំចិត្ត

**បិ.៥៣.ទំ.៩៧. ឥតិវុត្តក ស្តីអំពី អកុសលវិត្តក ៣ យ៉ាង**

*ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្កនេះមាន ៣ ។ អកុសលវិតក្ក ៣ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ គឺវិតក្កៈដែលប្រកបដោយសេចក្តីប្រាថ្នាមិនឱ្យអ្នកដទៃមើលងាយខ្លួន ១ វិតក្កៈដែលប្រកបដោយលាភសក្ការៈ និងសេចក្តីសរសើរ ១ វិតក្កៈ ដែលប្រកបដោយសេចក្តីអាណិតបុគ្គលដទៃ ១ ។ ម្នាលភិក្ខុទាំងឡាយ អកុសលវិតក្កៈមាន ៣ នេះឯង ។ លុះព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនេះថា:*

**អនវញ្ញត្តិសញ្ញុត្តោ លាភសក្ការគារវោ**
**សហនន្ទិ អមច្ចេហិ អារា សំយោជនក្ខយា ។**
**យោច បុត្តេ បសុំ ហិត្វា វិវាហេ សង្គហានិច**
**ភព្វោ សោ តាទិសោ ភិក្ខុ ផុដ្ឋុំ សម្ពោធិមុត្តមន្តិ ។**

*បុគ្គលណាមួយ ប្រកបដោយសេចក្តីប្រាថ្នា មិនឱ្យអ្នកដទៃមើលងាយខ្លួន ជាអ្នកធ្ងន់ក្នុងលាភនិងសក្ការ មានសេចក្តីរីករាយជាមួយនឹងពួកអាមាត្យ បុគ្គលនោះឈ្មោះថា ឆ្ងាយអំពីការអស់ទៅនៃសំយោជនៈ ។*

*បុគ្គលណាមួយក្នុងលោកនេះ លះបង់បុត្តនិង ភរិយាផង លះបង់សត្វចិញ្ចឹមផង លះបង់សេចក្ដីសង្គ្រោះក្នុងវិវាហៈផង ភិក្ខុប្រាកដដូច្នោះ នោះគួរដើម្បីបាននូវសម្ពោធិដ៏ឧត្តម ។*

## លក្ខណាទិចតុក្ករបស់មនោធាតុ

-**ចក្ខុវិញ្ញាណាទីនំ អនន្តរូបាទី វិជានន លក្ខណា** *មានការដឹងនូវរូបារម្មណ៍ជាដើម ក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើម ជាលក្ខណៈ*

-**រូបាទីនំ សម្បដិច្ឆន្នា រសោ** *មានការទទួលអារម្មណ៍មានរូបារម្មណ៍ទាំងនោះ ជាកិច្ច*

-**ចក្ខុវិញ្ញាណាទិ អបគមន បច្ចុប្បដ្ឋានា** *មានការៈដូចការទទួលអារម្មណ៍ទាំងនោះ ជាផល*

-**ចក្ខុវិញ្ញាណាទិ អបគមន បទដ្ឋានា** *មានការរលត់ទៅនៃវិញ្ញាណមានចក្ខុវិញ្ញាណជាដើម ជាហេតុជិត ។*

✍📖🕯

# ធម៌អប់រំចិត្ត

បិ.៥៣.ទំ.១០០. ឥតិវុត្តក ស្តីអំពី សំឡេងទេវតា ៣ យ៉ាង

ម្នាលភិក្ខុទាំងឡាយ សម្លេងទេវតា ៣ យ៉ាងនេះ តែងលាន់ឮក្នុងទេវលោក ព្រោះអាស្រ័យសម័យនោះ ។ សម្លេង ៣ យ៉ាង តើដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ សម័យណាអរិយសាវ័កគិត ដើម្បីកោរសក់ពុកចង្កា ស្លៀកសំពត់កាសាយៈទាំងឡាយ ហើយចេញចាកផ្ទះចូលទៅផ្នួស ម្នាលភិក្ខុទាំងឡាយ សម័យនោះ សម្លេងទេវតាក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើងថា អរិយសាវ័កនុ៎ះ គិតដើម្បីច្បាំងនឹងកិលេសមារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសម្លេងទេវតាទី ១ ក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើងព្រោះអាស្រ័យសម័យនោះៗ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត សម័យណាអរិយសាវ័កប្រកបរឿយៗនូវព្យាយាម ដើម្បីចម្រើននូវពោធិបក្ខិយធម៌៧ពួក ម្នាលភិក្ខុទាំងឡាយ សម័យនោះសម្លេងទេវតាក្នុងលោកទាំងឡាយ តែងលាន់ឮឡើងថា អរិយសាវ័កនុ៎ះ កំពុងច្បាំងនឹងកិលេសមារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសម្លេងទេវតាទី ២ ក្នុងទេវលោកទាំងឡាយតែងលាន់ឮឡើង ព្រោះអាស្រ័យសម័យនោះៗ ។

*ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សម័យណាអរិយសាវ័កធ្វើឱ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ម្នាលភិក្ខុទាំងឡាយ សម័យនោះ សម្លេងទេវតាក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើងថា អរិយសាវ័កនុ៎ះឈ្នះសង្គ្រាមហើយ ឈ្នះដ៏រាបគ្របសង្កត់នូវកំពូលនៃសង្គ្រាមក្នុងទេវលោកទាំងឡាយ តែងលាន់ឮឡើង ព្រោះអាស្រ័យសម័យនោះៗ ។ ម្នាលភិក្ខុទាំងឡាយ សម្លេងនៃទេវតាក្នុងទេវលោកទាំងឡាយ មាន ៣ យ៉ាងនេះឯង តែងលាន់ឮឡើង ព្រោះ អាស្រ័យសម័យនោះ ។*

**ទិស្វា វិជិតសង្គាមំ សម្មាសម្ពុទ្ធសាវកំ**
**ទេវតាបិ នមស្សន្តិ មហន្តំ វីតសារទំ**
**នមោ តេ បុរិសាជញ្ញ យោ ត្វំ ទុជ្ជយមជ្ឈគូ**
**ជេត្វាន មច្ចុនោ សេនំ វិមោក្ខេន អនាវរំ**
**ឥតិ ហេតំ នមស្សន្តិ ទេវតា បត្តមានសំ**
**តញ្ហិ តស្ស ន បស្សន្តិ យេន មច្ចុវសំ វជេ តិ។**

*ពួកទេវតា បានឃើញសាវ័កនៃព្រះសម្មាសម្ពុទ្ធដែលឈ្នះសង្គ្រាមហើយ លោក មានគុណដ៏ធំប្រាសចាកសេចក្ដីកោតញញើត ទើបនមស្ការថា បពិត្របុរសអាជានេយ្យ អ្នកណាបានបង្ក្រាបសង្គ្រាមដែលគេឈ្នះបានដោយកម្រ បានឈ្នះសេនានៃមច្ចុ ដែល*

បុគ្គលដទៃ មិនអាចឃាត់ខាំងបានដោយវិមោក្ខ ខ្ញុំសូមនមស្ការអ្នកនោះ ព្រោះហេតុនោះ ពួកទេវតាតែងនមស្សការនូវព្រះសាវ័កនៃព្រះសម្មាសម្ពុទ្ធនុ៎ះ ដែលមានសេចក្តីប្រាថ្នាសម្រេចហើយ សាវ័កនៃព្រះសម្មាសម្ពុទ្ធ គប្បីដល់នូវអំណាចនៃមច្ចុទៀត ដោយហេតុណា ពួកទេវតាមិនឃើញហេតុនោះ របស់សាវ័កនៃព្រះសម្មាសម្ពុទ្ធនោះឡើយ ។

## ហេតុឱ្យកើតមនោវិញ្ញាណធាតុ ៧៦ មាន៤ គឺ

**១.មនោទ្វារ** បានដល់កវង្គចិត្ត ១៩ គឺឧបេក្ខាសន្តីរណចិត្ត ២ ដួង មហាវិបាកចិត្ត៨ មហគ្គតវិបាកចិត្ត ៩

**២.អារម្មណ** បានដល់រូបារម្មណ៍ជាដើម រហូតដល់ធម្មារម្មណ៍

**៣.ហទយវត្ថុ** បានដល់ហទយវត្ថុ

**៤.មនសិការ** មានសេចក្តីតាំងចិត្ត។

## ហេតុឱ្យកើតមនោវិញ្ញាណធាតុម៉្យាងទៀត

**១.អសម្ភិន្នត្តា មនស្ស** ដោយមនោនៅមិនទាន់បែកធ្លាយ

**២.អាបាថគតត្តា ធម្មានំ** ដោយធម៌ទាំងឡាយមកកាន់គន្លង

**៣.វត្ថុសន្និស្សិតំ** អាស្រ័យវត្ថុ

**៤.មនសិការហេតុកំ** មានមនសិការជាហេតុ ។

*បណ្តាបច្ច័យទាំង ៤ នេះ ពាក្យថាមនោបានដល់ភវង្គចិត្ត ។ ភវង្គចិត្តនោះបែកធ្លាយហើយក្តី មានកម្លាំងខ្សោយមិនអាចជាបច្ច័យដល់អាវជ្ជនចិត្តបានក្តី ឈ្មោះថាបែកធ្លាយ ប៉ុន្តែពេលដែលអាចជាបច្ច័យដល់អាវជ្ជនចិត្ត បានឈ្មោះថានៅមិនទាន់បែកធ្លាយ ។*

*ពាក្យថា ធម៌ទាំងឡាយមកកាន់គន្លង បានដល់ធម្មារណ៍មកកាន់គន្លង ។ ពាក្យថាអាស្រ័យ ហទយវត្ថុគឺអាស្រ័យ បានតែហទយវត្ថុប៉ុណ្ណោះ ទើបកើតឡើង វៀរហទយវត្ថុក៏មិនកើត ។ បញ្ហានេះព្រះថេរៈលោកពោលសំដៅដល់បញ្ចវោការភព គឺភពដែលមានខន្ធ៥ ។ ពាក្យថាមានមនសិការជាហេតុ អធិប្បាយថាកិរិយាមនោធាតុញ៉ាំងភវង្គឱ្យផ្លាស់ប្តូរទៅសិន ទើបមនោវិញ្ញាណកើតឡើង ។*

# ធម៌អប់រំចិត្ត

បិ.៥២.ទំ.៩៨. គាថាធម្មបទ ស្តីអំពី ការសង្រួម

**ចក្ខុនា សំវរោ សាធុ សាធុ សោតេន សំវរោ**
**ឃានេន សំវរោ សាធុ សាធុ ជីវ្ហាយ សំវរោ**
**កាយេន សំវរោ សាធុ សាធុ វាចាយ សំវរោ**
**មនសា សំវរោ សាធុ សាធុ សព្វត្ថ សំវរោ**
**សព្វត្ថ សំវរោ ភិក្ខុ សព្វទុក្ខា បមុច្ចតិ**

*ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ*
*ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ*
*ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ*
*ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ*
*ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។*

ព្រះសម្ពុទ្ធសម្តែងប្រារព្ធចំពោះភិក្ខុ ៥ រូប

## លក្ខណាទិចតុក្ករបស់មនោវិញ្ញាណធាតុ

-**សឡារម្មណ វិជានន លក្ខណំ** *មានការដឹងអារម្មណ៍ ៦ ជាលក្ខណៈ*

-**សល្លីរណាទិ រសោ** *មានការពិចារណាអារម្មណ៍ ជាដើម ជានិច្ច*

-**តថាភាវ បច្ចុប្បដ្ឋានា** *មានសភាពជាយ៉ាងនោះ (មានការពិចារណាអារម្មណ៍ជាដើមយ៉ាងនោះ) ជាផល*

-**ហទយវត្ថុ បទដ្ឋនា** *មានហទយវត្ថុ ជាហេតុជិត ។*

## ធម៌អប់រំចិត្ត

បិ.៥២.ទំ.១០១.គាថាធម្មបទ ស្តីអំពី ការជម្រុះកិលេស

**វស្សិកា វិយ បុប្ផានិ មទ្ទវានិ បមុញ្ចតិ**
**ឯវំ រាគញ្ច ទោសញ្ច វិប្បមុញ្ចេថ ភិក្ខវោ**

*ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីជម្រុះរាគៈនិងទោសៈចេញ ដូចផ្កាម្លិះជម្រុះផ្កាទាំងឡាយ ដែលស្វិតហើយដូច្នោះ ។*

ព្រះសម្ពុទ្ធសម្តែងប្រារព្ធចំពោះភិក្ខុ ៥០០អង្គ

# អហេតុកកថាបន្ថែម

*អហេតុកចិត្ត ១៨ ជាវិញ្ញាណខន្ធ ជាមនាយតនៈ ។

*អហេតុកចិត្ត ១៨ ជាវិញ្ញាណធាតុ៧ គឺ:

-ចិត្ត២ដួង ជាចក្ខុវិញ្ញាណធាតុ១

-ចិត្ត២ដួង ជាសោតវិញ្ញាណធាតុ១

-ចិត្ត២ដួង ជាឃានវិញ្ញាណធាតុ១

-ចិត្ត២ដួង ជាជិវ្ហាវិញ្ញាណធាតុ១

-ចិត្ត៣ដួង ជាវិញ្ញាណធាតុ១

-ចិត្ត៥ដួង ជាមនោវិញ្ញាណធាតុ១

*អហេតុកចិត្ត ១៨ ដួង ជាទុក្ខសច្ច ជាមនិន្ទ្រិយ ។

*អហេតុកចិត្ត ១៨ដួង មាន២ជាតិ គឺ

-ចិត្ត១៥ដួង ជាវិបាកជាតិ

-ចិត្ត៣ដួង ជាកិរិយាជាតិ ។

*អហេតុកចិត្ត ១៨ដួង ជាកាមភូមិ កើតក្នុងភពផ្សេងៗគឺ

-ចិត្ត៦ កើតក្នុងកាមភូមិ១១

-ចិត្ត១០ កើតក្នុងភព២៦ គឺកាមភព ១១ រូបភព ១៥

-ចិត្ត១ កើតក្នុងភព ៣០

-ហសិតុប្បាទចិត្ត កើតនៅក្នុងភព ២២ គឺកាមសុគតិភព៧ រូបភព១៥ ។

*អហេតុកចិត្ត ១៨ ប្រកបដោយវេទនា៤ប្រភេទគឺ

-ចិត្ត១ដួង ប្រកបដោយសុខវេទនា

-ចិត្ត១ដួង ប្រកបដោយទុក្ខវេទនា

-ចិត្ត២ដួង ប្រកបដោយសោមនស្សវេទនា

-ចិត្ត១៤ដួង ប្រកបដោយឧបេក្ខាវេទនា ។

*អហេតុកចិត្ត ១៨ ជានហេតុ គឺមិនមែនជាតួហេតុ ជាវិប្បយុត្ត គឺប្រាសចាកអកុសលចេតសិក និងសោភណចេតសិក ។

*អហេតុកចិត្ត ១៨ ប្រកបជាមួយចេតសិក ១២គឺ

-ចិត្ត១០ដួង មួយដួងៗ មានចេតសិក ៧

-ចិត្ត៥ដួង មួយដួងៗ មានចេតសិក ១០

-ចិត្ត២ដួង មួយដួងៗ មានចេតសិក ១០

-ហសិតុប្បាទចិត្ត១ដួង មានចេតសិក ១២ ។

*អហេតុកចិត្ត ១៤ ដួង ធ្វើកិច្ចបានទាំង១៤គឺ

-ចិត្ត២ដួង មួយដួងៗធ្វើកិច្ចបាន៥គឺ បដិសន្ធិកិច្ច១ ភវង្គកិច្ច១ ចុតិកិច្ច១ សន្តីរណកិច្ច១ និងតទាលម្ពណកិច្ច១ ។

-ចិត្ត១ដួង ធ្វើកិច្ចបានពីរ គឺអាវជ្ជនកិច្ច១ វោដ្ឋវនកិច្ច១

-ចិត្ត១ដួង ធ្វើកិច្ចបានពីរ គឺសន្តីរណកិច្ច ១ និង តទាលម្ពណកិច្ច១ ។

-ចិត្ត១ដួង ធ្វើអាវជ្ជនកិច្ច

-ចិត្ត២ដួង ធ្វើទស្សនកិច្ច

-ចិត្ត២ដួង ធ្វើសវនកិច្ច

-ចិត្ត២ដួង ធ្វើឃាយនកិច្ច

-ចិត្ត២ដួង ធ្វើសាយនកិច្ច

-ចិត្ត២ដួង ធ្វើផុស្សនកិច្ច

-ចិត្ត២ដួង ធ្វើសម្បដិច្ឆនកិច្ច

-ហសិតុប្បាទចិត្ត១ដួង ធ្វើជវនកិច្ច ។

*អហេតុកចិត្ត ១៨ ដួងកើតតាមទ្វារដូចតទៅ ៖

-ចក្ខុវិញ្ញាណ២ដួង កើតតាមចក្ខុទ្វារ

-សោតវិញ្ញាណ២ដួង កើតតាមសោតទ្វារ

-ឃានវិញ្ញាណ២ដួង កើតតាមឃានទ្វារ

-ជីវ្ហាវិញ្ញាណ២ដួង កើតតាមជីវ្ហាទ្វារ

-កាយវិញ្ញាណ២ដួង កើតតាមកាយទ្វារ

-មនោធាតុ៣ដួង កើតតាមបញ្ចទ្វារ

-អហេតុកកិរិយាមនោវិញ្ញាណ ២ ដួង និងអហេតុកវិបាកមនោវិញ្ញាណ ប្រកបជាមួយសោមនស្សវេទនា ១ ដួង កើតតាមទ្វារ ៦ ។

-អហេតុកវិបាកមនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខាវេទនា ២ ដួង កើតតាមទ្វារ៦ ក៏មាន ក្រៅទ្វារ៦ក៏មាន ។

*អហេតុកចិត្ត ១៨ ដឹងអារម្មណ៍ដូចតទៅ

-ចក្ខុវិញ្ញាណ២ដួង មានរូបបច្ចុប្បន្ន ជាអារម្មណ៍

-សោតវិញ្ញាណ២ដួង មានសម្លេងបច្ចុប្បន្ន ជាអារម្មណ៍

-ឃានវិញ្ញាណ២ដួង មានក្លិនបច្ចុប្បន្ន ជាអារម្មណ៍

-ជីវ្ហាវិញ្ញាណ២ដួង មានរសបច្ចុប្បន្ន ជាអារម្មណ៍

-កាយវិញ្ញាណ២ដួង មានផោដ្ឋព្វៈបច្ចុប្បន្ន ជាអារម្មណ៍

-មនោធាតុ៣ មានអារម្មណ៍តាមបញ្ចទ្វារ ជាបច្ចុប្បន

-អហេតុកវិបាកមនោវិញ្ញាណ ៣ និងអហេតុកកិរិយាមនោ-វិញ្ញាណធាតុ ប្រកបដោយសោមនស្សវេទនា (ហសិតុប្បាទ) ១ មានអារម្មណ៍ ជាកាមវចរគ្រប់កាលទាំង ៣ ។

-អហេតុកកិរិយាមនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខា-វេទនា មានអារម្មណ៍ទាំងអស់ផង គ្រប់កាលទាំង៣ផង ។

-ចិត្ត១៣ដួង មានរូបធម៌ជាអារម្មណ៍

-ចិត្ត៤ដួង មានរូបធម៌ នាមធម៌ ជាអារម្មណ៍

-ចិត្ត១ដួង មានរូបធម៌ នាមធម៌ បញ្ញត្តិ និព្វាន ជាអារម្មណ៍

-ចិត្ត១៧ មានកាមាវចរ ជាអារម្មណ៍

-ចិត្ត១ មានកាមាវចរ ជាមហគ្គត លោកុត្តរ បញ្ញត្តិ ជាអារម្មណ៍

*អហេតុកចិត្ត ១៨ ដួង អាស្រ័យវត្ថុរូបដូចតទៅ

-ចក្ខុវិញ្ញាណ២ដួង អាស្រ័យចក្ខុវត្ថុ

*-សោតវិញ្ញាណ២ដួង អាស្រ័យសោតវត្ថុ*

*-ឃានវិញ្ញាណ២ដួង អាស្រ័យឃានវត្ថុ*

*-ជីវ្ហាវិញ្ញាណ២ដួង អាស្រ័យជីវ្ហាវត្ថុ*

*-កាយវិញ្ញាណ២ដួង អាស្រ័យកាយវត្ថុ*

*-ចិត្ត៧ដួងដទៃ អាស្រ័យហទយវត្ថុ*

*-អហេតុកកិរិយាមនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខា-វេទនា បើនៅក្នុងបញ្ចវោការភព ភពដែលមានខន្ធ ៥ អាស្រ័យហទយវត្ថុ បើនៅក្នុងអរូបព្រហ្ម មិនអាស្រ័យនូវហទយវត្ថុឡើយ ។*

**គាថាសង្គហៈ**

**សត្តាកុសលបាកានិ បុញ្ញបាកានិ អដ្ឋធា**
**ក្រិយាចិត្តានិ តីណីតិ អដ្ឋារស អហេតុកា**

*អកុសលវិបាកចិត្ត ៧ អហេតុកកុសលវិបាកចិត្ត ៨*
*អហេតុកកិរិយា៣ រួមចិត្ត១៨ដួងនេះ ជាអហេតុកចិត្ត ។*

*ពាក្យគួរចេះ*

| |
|---|
| អំពើអាក្រក់ មនុស្សអាក្រក់ធ្វើដោយងាយ |

# វេទនានុបស្សនាសតិប្បដ្ឋាន
## ពាក្យថាវេទនា

**វេទនា** *ជាសភាវៈធម៌ម៉្យាងក្នុងសភាវៈធម៌ទាំងពួង វេទនានេះ ជាចេតសិកធម៌ ក្នុងចេតសិកទាំង ៥២ មានវេទនាចេតសិក១នេះផងដែរ ។ វេទនាមានវិគ្រោះថា* **វេទិយតិ អារម្មណរសំ អនុភវតីតិ** > **វេទនា** (*ដែលឈ្មោះថា វេទនា ព្រោះអត្ថថា ដឹងខ្លួន គឺសោយរសនៃអារម្មណ៍*)។

*<u>សួរ.</u>សម្បយុត្តធម៌ក្រៅពីវេទនាមិនមានការសោយអាម្មណ៍ទេឬ ?*

*<u>ឆ្លើយ.</u> សម្បយុត្តធម៌ក្រៅពីវេទនា មានការសោយរសនៃអារម្មណ៍ដែរ តែសោយត្រឹមបានតែមួយ មួយចំណែករបស់ខ្លួនប៉ុណ្ណោះ ប៉ុន្តែចំពោះវេទនានេះ តែងសោយរសនៃអារម្មណ៍ដោយត្រង់ ។*

*នៅក្នុងព្រះអដ្ឋកថា នៃគម្ពីរធម្មសង្គណី ឈ្មោះអដ្ឋសាលនី លោកបានប្រៀបធៀបថា: វេទនាប្រៀបដូចជាព្រះរាជា អ្នកសោយនូវព្រះក្រយាហារ ចំណែកចិត្ត និងចេតសិកដទៃៗ ដែលកើតរួមជាមួយប្រៀបបីដូចអ្នកដាំស្ងោឱ្យព្រះរាជាមានសិទ្ធិ ត្រឹមតែភ្លក្សអាហារតិចតួចតាមសមគួរប៉ុណ្ណោះ មិនដូចព្រះរាជាមានសិទ្ធិបរិបូរណ៍ ក្នុងការសោយ ។*

*ម្យ៉ាងទៀត វេទនានោះ កាលបើចំណែកតាមអារម្មណ៍* **អារម្មណានុភវនលក្ខណន័យ** *គឺន័យមានការសោយអារម្មណ៍ លក្ខណៈមានវេទនាបី៣គឺសុខវេទនា១ ទុក្ខវេទនា១ អទុក្ខមសុខ-វេទនា ១ ប៉ុន្តែបើចំណែកតាមឥន្ទ្រីយ៍ក៏បាន វេទនា ៥ គឺ សុខ-វេទនា ១ ទុក្ខវេទនា ១ សោមនស្សវេទនា ១ ទោមនស្សវេទនា ១ ឧបេក្ខាវេទនា ១ ។*

## លក្ខណាទិចតុករបស់វេទនា

- **អនុភវន លក្ខណា** *មានការសោយអារម្មណ៍ ជាលក្ខណៈ*
-**វិសយរសសម្ភោគ រសា** *មានការប្រសព្វនឹងរសអារម្មណ៍ ជាកិច្ច*
- **សុខទុក្ខ បច្ចុប្បដ្ឋានា** *មានសុខនិងទុក្ខជាផល*
-**ផស្សបទដ្ឋានា** *មានផស្សៈជាហេតុជិត។*

## លក្ខណាទិចតុករបស់សុខវេទនា

-**ឥដ្ឋផោដ្ឋព្វានុភវ លក្ខណា** *មានការសោយផោដ្ឋព្វៈគួរជាទីប្រាថ្នាជាលក្ខណៈ*
-**សម្បយុត្តានំ ព្រូហន រសា** *មានការធ្វើសម្បយុត្តធម៌ឱ្យចម្រើន ជាកិច្ច*
-**កាយិកអស្សាទ បច្ចុប្បដ្ឋានា** *មានការសប្បាយកាយ ជាផល*
-**កាយិន្ទ្រិយ បទដ្ឋានា** *មានកាយបសាទជាហេតុជិត ។*

## លក្ខណាទិចតុក្ករបស់ទុក្ខវេទនា

-**អនិដ្ឋផោដ្ឋព្វានុភវន លក្ខណា** *មានការសោយរស់នៃអារម្មណ៍ ដែលមិនគាប់ចិត្តជាលក្ខណៈ*

-**សម្បយុត្តានំ មិលាបន រសា** *មានការធ្វើសម្បយុត្តធម៌ឱ្យថយចុះ ឱ្យសៅហ្មងជាកិច្ច*

-**កាយិកាពាធ បច្ចុប្បដ្ឋានា** *មានការអាពាធកាយជាផល*

-**កាយិន្ទ្រិយ បទដ្ឋានា** *មានកាយបសាទជាហេតុជិត ។*

## លក្ខណាទិចតុក្ករបស់សោមនស្សវេទនា

-**ឥដ្ឋារម្មណានុភវន លក្ខណា** *មានការសោយអារម្មណ៍ដែលគាប់ចិត្ត ជាលក្ខណៈ*

-**ឥដ្ឋាការសម្ភោគ រសា** *មានការប្រសព្វនឹងអាការៈដែលជាទីប្រាថ្នា ជាកិច្ច*

-**ចេតសិក អស្សាទ បច្ចុប្បដ្ឋានា** *មានការសប្បាយចិត្តជាផល*

- **បស្សទ្ធិ បទដ្ឋានា** *មានការស្ងប់កាយស្ងប់ចិត្តជាហេតុជិត ។*

## លក្ខណាទិចតុក្ករបស់ទោមនស្សវេទនា

-**អនិដ្ឋារម្មណានុភវន លក្ខណា** *មានការសោយអារម្មណ៍ដែលមិនគាប់ចិត្ត ជាលក្ខណៈ ។*

-**អនិដ្ឋារម្មណ៍ សោ** *មានការប្រសព្វនឹងអារម្មណ៍មិនជាទីប្រាថ្នាជាកិច្ច ។*

-**ចេតសិកពាធ បច្ចុប្បដ្ឋានា** *មានការអាពាធចិត្តជាផល*

-**ឯកន្តេនេវ ហទយវត្ថុ បទដ្ឋានា** *មានទយវត្ថុជាហេតុជិត ។*

## លក្ខណាទិចតុក្ករបស់ឧបេក្ខាវេទនា

-**មជ្ឈត្តវេទយិត លក្ខណា** *មានការសោយអារម្មណ៍ ជាកណ្តាល ជាលក្ខណៈ ។*

-**សម្បយុត្តានំ នាតិ ឧបព្រូហន មិលាបន រសា** *មានការរក្សា សម្បយុត្តធម៌មិនឱ្យចម្រើន និងមិនឱ្យសៅហ្មងវិនាសជាកិច្ច ។*

-**សន្តិភាវ បច្ចុប្បដ្ឋានា** *មានសេចក្តីស្ងប់ជាផល ។*

-**និប្បីតិកចិត្ត បទដ្ឋានា** *មានចិត្តដែលមិនប្រកបដោយបីតិ ជាហេតុជិត ។*

<u>ពាក្យគួរចេះ</u>

| | |
|---|---|
| ព្រះធម៌មានហើយ | ចូរកុំកន្ដើយខិតខំសិក្សា |
| ទាន់ធម៌នៅមាន | រៀនពិចារណា |
| ចង់ឈ្នះចាញ់គ្នា | បានប្រយោជន៍អ្វី ។ |

⇨...ដោយឧបាសក**គុយ សុធន**

# សេចក្តីពន្យល់បន្ថែមអំពីវេទនា

នៅក្នុងគម្ពីរសម្មោហវិនោទនី អដ្ឋកថាព្រះអភិធម៌គម្ពីរវិភង្គមានពាក្យជាបាលីថា **ផស្សេន សម្បយុត្តោ** ប្រែថា សម្បយុត្តដោយផស្សៈ គឺមានសេចក្តីថាវេទនាមានផស្សៈ ជាបច្ច័យ ឬ វេទនាកើតរួមជាមួយផស្សៈ ។ វេទនាជាប្រភេទនៃនាមធម៌មួយបែបធ្វើកិច្ចសោយនូវអារម្មណ៍ ទាំងដែលអារម្មណ៍មកប្រាកដនោះ ក៏ត្រូវមានផស្សៈជាបច្ច័យ ។

ក្នុងសាសនាព្រហ្មចរិយៈនៃព្រះពុទ្ធសាសនា ដូចដែលព្រះសម្មាសម្ពុទ្ធសម្តែងមកដោយច្រើន គឺព្រះអង្គទ្រង់សម្តែងអំពីការពិតនៃជីវិត ដូចព្រះអង្គសម្តែងអំពីសតិប្បដ្ឋានសូត្រ ក្នុងព្រះសូត្រនេះ បើពុទ្ធបរិស័ទសិក្សាដោយល្អ រៀនសូត្រដោយល្អ ពិចារណាដោយល្អហើយ អ្នកសិក្សានោះ អ្នករៀនសូត្រនោះ អ្នកអប់រំពិចារណានោះ នឹងបាននូវសេចក្តីសុខស្ងប់ចិត្តជាក់ជាពុំខាន ។ ព្រោះថាក្នុងសតិប្បដ្ឋានមួយៗខាងចុងនៃសតិប្បដ្ឋាននោះ ។ លោកបានបញ្ជាក់ថា ដើម្បីកំចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ព្រះសម្មាសម្ពុទ្ធព្រះអង្គត្រាស់ជាសំនួរដោយ បទបាលីថា

**កថញ្ច ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ**

ប្រែជាសេចក្តីថា ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញ

នូវវេទនាក្នុងវេទនាទាំងឡាយ ជាប្រក្រតីគ្រប់ឥរិយាបថទាំង៤ តើដោយវិធីដូចម្តេច ? ព្រះសម្មាសម្ពុទ្ធ ព្រះអង្គត្រាស់សួររួចហើយ ព្រះអង្គទ្រង់ ឆ្លើយដោយព្រះអង្គឯង ដោយបទបាលីថា ៖

**ឥធ ភិក្ខវេ ភិក្ខុ សុខំ វា វេទនំ វេទយមានោ សុខំ វេទនំ វេទយាមីតិ បជានាតិ ទុក្ខំ វា វេទនំ វេទយមានោ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ អទុក្ខមសុខំ វា វេទនំ វេទយមនោ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ ។**

ប្រែសេចក្តីថា: ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសោយសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញសោយសុខវេទនា កាលសោយទុក្ខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញសោយទុក្ខវេទនា កាលសោយអទុក្ខមសុខវេទនាក្តី ក៏ដឹងច្បាស់ថាអាត្មាអញសោយអទុក្ខមសុខវេទនាជាដើម ។

បុគ្គលដែលបានអប់រំចម្រើនបញ្ញា ក្នុងការប្រច័ក្សច្បាស់ចំពោះសភាវៈធម៌ដែលកំពុងប្រាកដនៅ បុគ្គលនោះឈ្មោះថាកំពុងតែរើបំរះខ្លួនឱ្យផុតអំពីឧបាទានក្ខន្ធ ។ ព្រោះថាប្រក្រតីនៃជីវិតប្រចាំថ្ងៃ សម្បូរណ៍ក្នុងរឿងប្រកាន់ ឧទាហរណ៍ អង្គុយយូរទៅពោយស្រពន់ដៃជើង ចុកចង្កេះ ពេលនោះសួរថា តើបានកំណត់ឱ្យដឹង ថាត្រឹមតែជាវេទនាទេ គឺឆ្លើយថា បានកំណត់ដឹងដែរ តែង

*កំណត់ដឹងថា ខ្ញុំឈឺចង្កេះខ្ញុំចុកពោយស្រពន់ដៃជើង នេះជាការបញ្ជាក់ឱ្យឃើញថា ការពិតរបស់ឧបាទានក្ខន្ធ គឺវាអ៊ីចឹង ។*

*<u>សួរ</u> ព្រោះហេតុអ្វី ?*

*<u>ឆ្លើយ</u> ព្រោះវាអ៊ីចឹង ។ ឆ្លើយយ៉ាងនេះស្តាប់បានទេ មើលយល់ទេ គិតឃើញទេ នឹកដល់ទេ ។ សភាពងងឹតរបស់អវិជ្ជាតែងតែបិទបាំងនូវសភាវៈគ្រប់យ៉ាងអស់ មិនឱ្យឃើញច្បាស់ចំពោះសភាវៈពិតឡើយ ។*

*វេទនាគ្រប់យ៉ាងទាំងអស់ត្រឹមតែជាធាតុ ទោះវេទនាទាំងនោះជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ជាខាងក្រៅក្តី ជាខាងក្នុងក្តី លិ្អតក្តី គ្រោតគ្រាតក្តី ថោកទាបក្តី ប្រណីតក្តី ជិតក្តី ឆ្ងាយក្តី រួបរួមទៅត្រឹមតែវេទនាប៉ុណ្ណោះ ។ វេទនាមានពិត តែវេទនាមិនមែនស្រីប្រុស មិនមែនសត្វបុគ្គល មិនមែនជាតួខ្លួនណាឡើយ ព្រោះតែកាលណាមានសម្ផស្សទាំង ៦ កើតឡើងជាបច្ច័យហើយ វេទនា គឺការសោយអារម្មណ៍ជាសុខក្តី ជាទុក្ខក្តី មិនសុខក្តី មិនទុក្ខក្តី ក៏រមែងកើតឡើង ។*

*វេទនាជាគំនររបស់សង្ខារធម៌ ដែលមានឈ្មោះថាវេទនាខន្ធ ចំពោះខន្ធទាំង៥ ក្នុងនោះមានខន្ធមួយ ឈ្មោះថាវេទនាខន្ធ ដូច្នេះការបដិបត្តិធម៌ ដើម្បីចេញចាកអំពីខន្ធ ព្រោះខន្ធជាតួទុក្ខ (**នត្ថិ ខន្ធា សមា ទុក្ខា** ទុក្ខណាៗស្មើដោយខន្ធពុំមានឡើយ)។*

*ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្តែងពន្យល់ អំពីការអប់រំចម្រើននូវវេទនានុបស្សនាសតិប្បដ្ឋាន ទាំងបាលីនឹងសេចក្តីប្រែដូចតទៅនេះថា ៖*

**ឥធ ភិក្ខវេ ភិក្ខុ សុខំ វា វេទនំ វេទយមានោ សុខំ វេទនំ វេទយាមីតិ បជានាតិ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសោយសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញសោយសុខវេទនា ។*

**ឥធ ភិក្ខវេ ភិក្ខុ ទុក្ខំ វា វេទនំ វេទយមានោ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសោយទុក្ខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញសោយទុក្ខវេទនា ។*

**ឥធ ភិក្ខវេ ភិក្ខុ អទុក្ខមសុខំ វា វេទនំ វេទយាមីតី បជានាតិ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសោយអទុក្ខមសុខវេទនា ក៏ដឹងច្បាស់ថាអាត្មាអញសោយអទុក្ខមសុខ-វេទនា ។*

**ឥធ ភិក្ខវេ ភិក្ខុ សាមិសំ វា សុខំ វេទនំ វេទយមានោ សាមិសំ វេទនំ វេទយាមីតិ បជានាតិ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសោយសុខវេទនា ប្រកបដោយអាមិសក្តី ក៏ដឹងច្បាស់ថាអាត្មាអញសោយសុខវេទនា ប្រកប*

*ដោយអាមិស ក៏ដឹងច្បាស់ថា អាត្មាអញសោយទុក្ខវេទនា ដែលប្រកបដោយអាមិស ។*

**ឥធ ភិក្ខវេ ភិក្ខុ និរាមិសំ វា សុខំ វេទនំ វេទយមានោ និរាមិសំ សុខំ វេទនំ វេទយាមីតិ បជានាតិ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសោយសុខវេទនា ដែលឥតអាមិសក្តី ក៏ដឹងច្បាស់ថា អាត្មាសោយសុខវេទនា ដែលឥតអាមិស ។*

**ឥធ ភិក្ខវេ ភិក្ខុ សាមិសំ វា វេទយមានោ សាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសោយទុក្ខវេទនា ប្រកបដោយអាមិសៈ ។*

**ឥធ ភិក្ខវេ ភិក្ខុ និរាមិសំ វា ទុក្ខំ វេទនំ វេទយមានោ និរាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសោយទុក្ខវេទនា ដែលឥតអាមិស ក៏ដឹងច្បាស់ថា អាត្មាសោយទុក្ខវេទនា ដែលឥតអាមិស ។*

**ឥធ ភិក្ខវេ ភិក្ខុ សាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ សាមិសំ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសោយអទុក្ខមសុខវេទនាប្រកបដោយអាមិសក៏ដឹងច្បាស់ថាអាត្មាសោយអទុក្ខមសុខវេទនា ប្រកបដោយអាមិស ។*

**ឥធ ភិក្ខវេ ភិក្ខុ និរាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ និរាមិសំ អទុក្ខមសុខំ វេទយាមីតិ បជានាតិ** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសោយអទុក្ខមសុខវេទនា ដែលឥតអាមិស ក៏ដឹងច្បាស់ថា អាត្មាអញសោយអទុក្ខមសុខវេទនាដែលឥតអាមិស ។*

## អានិសង្សរបស់វេទនា

**យំ វេទនំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វេទនាយ អស្សាទោ** *សេចក្ដីសុខសោមនស្សណា កើតឡើងព្រោះអាស្រ័យវេទនា នេះជាអានិសង្សរបស់វេទនា ។*

## កាលរលាស់ចោលនូវវេទនា

**ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ វេទនាយ និស្សរណំ** *កាលបន្ទោបង់នូវឆន្ទរាគៈ ការលះបង់នូវឆន្ទរាគៈណាក្នុងវេទនានេះ ជាការរលាស់ចេញនូវវេទនា ។*

## ត្រេកអរនឹងវេទនាឈ្មោះត្រេកអរនឹងទុក្ខ

**យោ វេទនំ អភិនន្ទតិ ទុក្ខំ សោ អភិនន្ទតិ**
**យោ ទុក្ខំ អភិនន្ទតិ អបរិមុត្តោ សោ ទុក្ខស្មាតិ**

**វនាមិ** *បុគ្គលណាត្រេកអរនឹងវេទនាបុគ្គលនោះឈ្មោះថាត្រេកអរនឹងទុក្ខ បុគ្គលណាត្រេកអរនឹងទុក្ខតថាគតហៅថាបុគ្គលនោះមិនរួចស្រឡះចាកវដ្តទុក្ខបានឡើយ ។*

## វិញ្ញាណរលត់ព្រោះអត់ត្រេកអរនឹងវេទនា

**អជ្ឈត្តញ្ច ពហិទ្ធា ច វេទនំ នាភិនន្ទតោ**
**ឯវំ សតស្ស ចរតោ វិញ្ញាណំ ឧបរុជ្ឈតិ**

*បុគ្គលកាលមិនត្រេកអរ ចំពោះវេទនាទាំងខាងក្នុងទាំងខាងក្រៅ មានសតិត្រាច់ទៅយ៉ាងនេះវិញ្ញាណរមែងរលត់ ។*

## វេទនាខន្ធជាអារម្មណ៍របស់សក្កាយទិដ្ឋិមាន ៤យ៉ាងគឺ

**១.វេទនំ អត្តនោ សមនុបស្សតិ** *ឃើញថាការសោយអារម្មណ៍ជាខ្លួន ខ្លួនគឺជាអ្នកសោយអារម្មណ៍*

**២.វេទនាវន្តំ វា អត្តានំ** *ខ្លួនមានការសោយអារមណ៍*

**៣.អត្តនិ វា វេទនំ** *ការសោយអារម្មណ៍នៅក្នុងខ្លួន*

**៤.វេទនាយ វា អត្តានំ** *យើងនៅក្នុងការសោយអារម្មណ៍ ។*

## ផ្លូវមួលតែមួយមិនមានពីរ

*នៅក្នុងគម្ពីរសុត្តន្តបិដក ទីឃនិកាយ មហាវគ្គ មហាសតិ-បប្បដ្ឋានសូត្រទី៩ ។ ក្នុងកាលនោះព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងជម្មាសទ្ធម្មនិគមរបស់អ្នកកុរុក្នុងដែនកុរុ ក្នុងកាលនោះឯងព្រះអង្គទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ*

ពួកភិក្ខុទាំងអស់នោះ ក៏ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ករុណាព្រះអង្គ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ៖ **ភគវា ឯតទវោច ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមត្តិកមាយ ទុក្ខទោមនស្សានំ អដ្ឋង្គិមាយ ញាយស អធិគមាយ សតិប្បដ្ឋានា** ម្នាលភិក្ខុទាំងឡាយផ្លូវ គឺសតិប្បដ្ឋាន ៤ នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីលះបង់នូវសេចក្តីសោក និងសេចក្តីខ្សឹបខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវអរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការ ដើម្បីឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

(ពោលអំពីវេទនានុបស្សនាសតិប្បដ្ឋានសង្ខេបចប់តែប៉ុណ្ណោះ )

# នាទីកំណាព្យ

*ឧបមាព្រះរតនត្រ័យ ២២ប្រការ*

វីគុណព្រះត្រៃរតន៍ បរិសុទ្ធប្រសើរក្រៃ
លោកបានឧបមេយ្យ មានម្ភៃពីរប្រការ។
*ទីមួយគឺព្រះពុទ្ធ ប្រសើរផុតត្រៃលោកា
ប្រៀបដូចព្រះចន្ទ្រា រះនាថ្ងៃពេញបូរមីណ៍ ។
រីឯព្រះធម្មា ប្រៀបដូចជាកាំរស្មី
នៃដួងព្រះច័ន្ទថ្លៃ ចាំងរស្មីភ្លឺលោកា។
ព្រះសង្ឃដូចលោកហ្នឹង បានទីពឹងព្រោះចន្ទ្រា
ចែងចាំងរស្មីថ្លា ឱ្យលោកាល្អពេកក្រៃ ។
*ទីពីរព្រះភគវា ប្រៀបដូចជាអាទិត្យថ្លៃ
រះឡើងនូវពេលថ្ងៃ មានរស្មីខ្លាំងមហិមា ។
ព្រះធម៌នៃព្រះអង្គ ផូរផង់ដូចអាភា
ចេញពីអាទិត្យថ្លា ដេញអន្ធការឱ្យខ្ចាត់ទៅ ។
ព្រះសង្ឃអង្គសាវ័ក មានសំរ:ល្អពេកកូវ
ដូចទ្វីបលោកដែលត្រូវ អាទិត្យក្តៅឱ្យភ្លឺថ្លា ។
*ទីបីព្រះមុនី ឥតមានពីរក្នុងលោកា
ព្រះអង្គប្រៀបដូចជា អ្នកដុតភ្លើងឈ្មួលដុតព្រៃ ។
រីអង្គព្រះធម្មា ប្រៀបដូចជាភ្លើងក្តៅក្រៃ
ដុតព្រៃស្មៅចង្រៃ ជាសត្រូវនឹងស្រែស្រូវ ។
ព្រះសង្ឃនោះឯងនៃ ឧបមេយ្យដូចដីស្រែ

ដែលម្ចាស់ខិតខំថៃ ក្លាយជាស្រែដ៏ឧត្តម
*ទីបួនព្រះភគវា ប្រៀបដូចជាភ្លៀងយ៉ាងធំ
ប្រយោជន៍ដ៏ឧត្តម តែងកើតមានដល់លោកា ។
ព្រះធម៌ព្រះទ្រង់ញាណ ដែលទ្រង់បានប្រោសទេសនា
ដូចដំណក់ទឹកថ្លា ស្រោចដណ្តប់លើផែនដី ។
សាវ័កអ្នកហ្មត់ចត់ ដូចជនបទពណ៌ខៀវខ្ចី
ដែលភ្លៀងទើបធ្លាក់ថ្មី គួរប្រុសស្រីទាក់នេត្រា ។
*ទីប្រាំព្រះសម្ពុទ្ធ ប្រសើរផុតជននានា
ព្រះអង្គប្រៀបដូចជា សារថីដ៏ចំណាប់ ។
រីឯព្រះធម៌ថ្លៃ ឧបមេយ្យដូចជាច្បាប់
ឧបាយជាគ្រឿងចាប់ បង្ហឹកសេះអាជានេយ្យ ។
ព្រះសង្ឃដ៏សោភា ប្រៀបដូចជាអាជានេយ្យ
ហ្វឹកហាត់ល្អប្រពៃ អាចលៃប្រើទាន់ចិន្តា ។
*ប្រាំមួយនោះឯង ល្អពេកក្រៃព្រះសាស្តា
ព្រះអង្គប្រៀបដូចជា សល្យពេទ្យសម្រាប់ដកសរ ។
ព្រះធម៌នៃព្រះអង្គ មានបែបទ្រង់សែនបវរ
ដូចឧបាយដកសរ គឺទិដ្ឋិសត្វគ្រប់គ្នា ។
សង្ឃសាវ័កកល្យាណ លោកប្រៀបបាននឹងអ្នកណា
ដែលសរមុតកាយា ត្រូវគ្រូពេទ្យដកចេញបាន ។
*ប្រាំពីរព្រះសម្ពុទ្ធ បរិសុទ្ធប្រៀបស្មើបាន
ចក្ខុពេទ្យចំណាន ចេះឧបាយបកនេត្រា ។

ព្រះធម៌វិសេសថ្លៃ ឧបមេយ្យឧបាយា
បកភ្នែកជននានា ឱ្យភ្លឺថ្លាផុតជម្ងឺ
រីឯព្រះសង្ឃា ប្រៀបដូចជាអ្នកភ្នែកឈឺ
ត្រូវពេទ្យបកឱ្យភ្លឺ ចាកងងឹតគឺមោហា ។
*ប្រាំបីព្រះភគវ័ន្ត អរហន្តជាសាស្តា
ព្រះអង្គប្រៀបដូចជា ពេទ្យមានប្រាជ្ញាឆ្លាតវៃ ។
ព្រះធម៌ដ៏កល្យាណ ប្រៀបស្មើបានឱសថថ្លៃ
ដែលពេទ្យមានស្នាដៃ ថ្លៃផ្សំត្រូវយ៉ាងចំណាន ។
ព្រះសង្ឃរតន៍ថ្លៃ ឧបមេយ្យអ្នកដែលបាន
សះស្បើយរោគសាមាន្យ គឺកិលេសគ្រប់ប្រការ ។
*ប្រាំបួនព្រះទ្រង់ញាណ ប្រៀបអ្នកបានស្គាល់មាគ៌ា
បង្ហាញសត្វគ្រប់គ្នា ឱ្យទៅរកទីផុតភ័យ ។
រីឯព្រះធម្មា ដែលសាស្តាទ្រង់លកលៃ
ត្រាស់ទុកដល់សព្វថ្ងៃ ឧបមេយ្យផ្លូវសុខា ។
ចំពោះព្រះសង្ឃរតន៍ បរិសុទ្ធឥតមាយា
ប្រៀបដូចប្រុសស្រីណា ដើរដល់ទីដែលក្សេមក្សាន្ត ។
*ទីដប់ព្រះសាស្តា មានបញ្ញារុងរឿងថ្កាន
ប្រៀបដូចព្រៃហេមពាន្ត ពេញទៅដោយដើមរុក្ខា ។
ព្រះធម៌ដូចដើមថ្នាំ ដុះប្រចាំគ្រប់វេលា
គុណភាពល្អអស្ចារ្យ នៅក្នុងទីព្រៃហេមពាន្ត ។
ព្រះសង្ឃល្អសោភា ប្រៀបដូចជាអ្នកដែលបាន

ឪសថព្រៃហេមពាន្ត ផឹករួចហើយស្បើយរោគា។
*ដប់មួយព្រះមានជោគ ដូចនាយទូកក្នុងជលសា
តែងមានចិត្តករុណា ដល់សព្វសត្វក្នុងភពត្រៃ ។
ព្រះធម៌ពាក្យទូន្មាន ប្រៀបស្មើបានទូកចរណៃ
ចម្លងផុតលោកត្រៃ ឱ្យដល់ត្រើយបានសុខា ។
ព្រះសង្ឃដ៏និមល ដូចអ្នកដល់ត្រើយហើយណា
ត្រើយនោះមានឈ្មោះថា ព្រះនិព្វានសែនសុខក្រៃ ។
*ដប់ពីរព្រះភគវា ជាសាស្តាបញ្ញាវៃ
ព្រះអង្គឧបមេយ្យ អ្នកឱ្យទ្រព្យគាប់ចិន្តា ។
ព្រះធម៌ទាំងប៉ុន្មាន ប្រៀបបានស្មើទ្រព្យនោះណា
ដែលជនផងនានា តែងប្រាថ្នារៀងរាល់ថ្ងៃ ។
សង្ឃាសាវ័កកល្យាណ ដូចអ្នកបានចាយទ្រព្យថ្លៃ
គុណភាពល្អពេកក្រៃ ចាយរួចបានសុខគួរគាប់ ។
*ដប់បីព្រះនិរភ័យ ឧបមេយ្យអ្នកមានភ័ព្វ
បង្ហាញរណ្តៅទ្រព្យ ឱ្យដល់អ្នកដែលត្រូវការ ។
ព្រះធម៌ពាក្យប្រៀនប្រដៅ ដូចរណ្តៅទ្រព្យនោះណា
ពេញដោយទ្រព្យនានា មានតម្លៃហួសការស្មាន ។
ព្រះសង្ឃអ្នកស្តាប់ទ្រង់ ផ្ទូរផង់រុងរឿងថ្កាន
ប្រៀបដូចអ្នកដែលបាន រណ្តៅទ្រព្យរីករាយក្រៃ ។
*ដប់បួនព្រះចមភព ល្អសព្វគ្រប់គ្មានទោសពៃ
ព្រះអង្គប្រសើរក្រៃ ដូចជាវីរៈបុរស ។

ព្រះធម៌ពាក្យបង្រៀន ប្រៀបស្មើបានក្តីផុតគ្រោះ
ក្សេមក្សាន្តឥតមានមោះ មានតែសុខគ្រប់ប្រការ ។
ព្រះសង្ឃដ៏សមទ្រង់ វិសុទ្ធិវង្សចិញ្ចែងថ្លា
ដូចអ្នកបានសុខា ដោយសារវីរៈបុរស ។
*ដប់ប្រាំព្រះសទ្ធម្ម បរិសុទ្ធសមទាំងអស់
ប្រៀបដូចសប្បុរស អ្នកលួងលោមឱ្យបានស្បើយ ។
រីព្រះសទ្ធម្មា ប្រៀបដូចការលួងនោះហើយ
លួងលោមឱ្យបានល្ហើយ ស្បើយក្តីសោកពោគចង្រៃ ។
ព្រះសង្ឃសាវ័កពុទ្ធ ដូចអ្នកផុតរួចចាកភ័យ
ឧបទ្រព្យកំណាចក្រៃ ព្រោះស្នាដៃនៃព្រះអង្គ ។
*ដប់ប្រាំមួយនោះណា ព្រះសាស្តាវិសុទ្ធវង្ស
ព្រះទ័យស្អាតស្មោះត្រង់ ប្រៀបប្រដូចនឹងមិត្តល្អ ។
រីឯពាក្យទេសនា បានរចនាជាបទធម៌
ដូចពាក្យមិត្តបវរ ប្រាប់ប្រយោជន៍ដល់មិត្តភ្វា ។
ព្រះសង្ឃឧត្តមពិត អ្នកនៃបនិត្យព្រះធម្មា
ប្រៀបដូចនឹងអ្នកណា បានប្រយោជន៍គាប់ហឫទ័យ ។
*ដប់ប្រាំពីរព្រះនិរទុក្ខ ល្អគ្រប់មុខហួសវិស័យ
ព្រះអង្គឧបមេយ្យ បឹងកើតទ្រព្យច្រើនប្រការ ។
ព្រះធម៌ល្អគួរគាប់ ដូចជាទ្រព្យមានខ្លឹមសារ
កើតក្នុងបឹងនោះណា ជនត្រូវការកើបយកបាន ។
ព្រះសង្ឃស្វាមីភ័ក្ត ប្រៀបដូចអ្នកសំណាងមាន

ដូបទ្រព្យបឹងកល្យាណ រមែងបានក្ដីរីករាយ ។
*ដប់ប្រាំបីព្រះសុគត ល្អវិសុទ្ធិមិនទន់ជ្រាយ
ប្រៀបធៀបអធិប្បាយ អ្នកភ្ជួតទឹករាជកុមារ ។
បណ្ដាំនៃព្រះអង្គ សមបែបទ្រង់គ្រប់ប្រការ
ប្រៀបដូចនឹងទឹកថ្លា សម្រាប់ងូតជម្រះកាយ ។
ព្រះសង្ឃប្រៀបដូចជា រាជកុមារបានសប្បាយ
ងូតទឹកត្រជាក់សាយ ជ្រះអស់ក្អែលពីកាយា ។
*ដប់ប្រាំបួនព្រះជិនស្រី មានសិរីឈ្នះក្រុងមារ
ព្រះអង្គប្រៀបដូចជា អ្នកធ្វើគ្រឿងប្រដាប់កាយ ។
ព្រះធម៌ពាក្យបណ្ដាំ ពីរពាន់ប្រាំរយឆ្នាំប្លាយ
ដូចគ្រឿងប្រដាប់កាយ ពេញនិយមគ្រប់វេលា ។
សាវ័កព្រះទ្រង់ញាណ ដែលលោកបានស្ដាប់ទេសនា
ដូចអ្នកល្អសោភា ព្រោះអលង្ការធម្មក្ខន្ធ ។
*ទីម្ភៃនោះឯងណា ឧបមាព្រះភគវន្ត
ដូចគ្នានឹងដើមចន្ទន៍ ប្រកបក្លិនមានតម្លៃ ។
រីឯព្រះសទ្ធម្ម ដ៏ឧត្តមសមប្រពៃ
ដូចក្លិនចន្ទន៍ចរណៃ ដែលប្រុសស្រីគួចប្រាថ្នា ។
សាវ័កអ្នកស្មោះត្រង់ អ្នកទ្រទ្រង់សីលសិក្ខា
ដូចជានរណា ស្រង់ក្លិនចន្ទន៍ឈ្ងុយពេកពិត ។
*ម្ភៃមួយព្រះបិតា ជាសាស្ដាទ្រង់មានឫទ្ធិ
ដូចផ្ដល់ទឹកអម្រឹត ដល់កូនស្ងួនទាំងប្រុសស្រី ។

វីព្រះសទ្ធម្មណា ដែលសាស្តាពោលស្រដី
ទេសនាយ៉ាងឃ្មាតខ្មី ប្រៀបដូចទឹកអម្រឹតហ្នឹង ។
ព្រះសង្ឃប្រៀបដូចជា អ្នកកំព្រាតតទីពឹង
បានទឹកអម្រឹតហ្នឹង មានពំនឹងរួចមរណា ។
*ម្តេពីរព្រះគោត្តម ដូចបទុមក្នុងជលសា
សូរ្យសែងរះកាលណា រីកសាខាស្រស់ឆើតឆាយ ។
ព្រះធម៌ប្រៀបដូចជា ទឹកអមផ្កាឈូកទាំងឡាយ
គួរស្រូបឥតជិតណាយ មាននូវក្នុងបទុមផ្កា ។
ព្រះសង្ឃអង្គសាវ័ក អ្នកជឿជាក់ត្រៃសិក្ខា
ប្រដូចនឹងភ្ញមរា បានក្រេបផ្កាក្នុងវារី ។
*ឧបមាគុណត្រៃរតន៍ មានប្រាកដម្តេពីរ
ដែលខ្ញុំសម្តី សូត្រវន្ទីយ៍នមស្ការ ។
សូមឱ្យសម្រេចបុណ្យ ដែលជាគុណល្អថ្លៃ
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។
សូមជួបព្រះសិរអារ្យ ជាសាស្តាដ៏ពិសិដ្ឋ
សូមចាក់ធ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

ដោយភិក្ខុ **សាន សុជា**

# ចាញ់បោកខន្ធ៥

ខន្ធអើយខន្ធ៥ ហេតុអ្វីមកនាំ ឱ្យខ្ញុំសោយសោក
វង្វេងវិលវល់ អំពលវិយោគ ខន្ធឯងប្រយោគ
បោកខ្ញុំដល់ណា ។

បើស្ដីពីខូច គ្មានអ្វីប្រដូច ស្មើបញ្ចខន្ធា
បោកប្រាស់សត្វលោក ក្នុងស្នូកអវិជ្ជា ខន្ធ៥នេះចាត់ជា
អ្នកលេងជើងស្រស់ ។

បោកខ្ទេចគ្មានសល់ សព្វសត្វសាកល ស្ត្រីឬបុរស
តែចេះស្មើៗ ខន្ធបោកទាំងអស់ បោកឥតស្រណោះ
អស់គ្រប់វិស័យ ។

ជូនឱ្យស្រលាញ់ ជំពាក់ខ្លួលខ្មាញ់ ដូចគុម្ពឫស្សី
តែភ្លាត់បន្តិច ធ្លាក់អវិចី ទំរាំកាត់ក្ដី
គិតថ្លៃមួយកប្ប ។

ជូននាំឱ្យខឹង សសៃកតឹង ហារឡើងសម្លាប់
ប៉ះលើមាតា បិតាពុំគាប់ ទំរាំរកច្បាប់
មួយកប្បដូចគ្នា ។

ខន្ធស្អីគេហ្នឹង បើតាមត្បាដឹង គេហៅថាមារ
វិកលខួរក្បាល ពេទ្យមើលមិនជា ឆ្កួតខន្ធារា
លំបាកកៃណាស់ ។

គ្មាមិនពោលលេង ក្មេងឆ្កួតតាមក្មេង ចាស់ឆ្កួតតាមចាស់
ចេញប្ញកបែបព្រើល ងងើលពកថ្ងាស ភ្លេចចាស់ឈឺស្លាប់
ព្រោះប្រាសស្មារតី ។

រីឯរូបក្ខន្ធ គ្មានអ្វីសំខាន់ ខ្យល់ទឹកភ្លើងដី
សង្ខារតាក់តែង ចាត់ចែងជើងដៃ ប៉ុណ្ណឹងទេរ៉ី
ចេះឆ្កួតចឹងដែរ ។

បើឆ្កួតយ៉ាងហ្នឹង តាមដោយគ្មាដឹង មិនងាយគ្រូកែ
ច្បាស់ជាទឹកភ្នែក យំយែកឥតល្ហែ ព្រោះឆ្កួតដុះស្លែ
ច្រើនថ្ងៃខែហើយ ។

ឆ្កួតស្រាមិនស្វាង ឆ្កួតខន្ធគ្រប់យ៉ាង មិនងាយសះស្បើយ
តាមការគន់គូរ ឆ្កួតគ្រូខាងម្ដាយ បើគ្រូទស្សន៍ទាយ
ឆ្កួតគ្រូខាងឪ ។

អ្នកឆ្កួតខន្ធ៥ បើតាមគ្មាចាំ លោកថាអស់ផ្លូវ
ចូលក្នុងវង្វេង អន្លង់ជ្រោះជ្រៅ ច្បាស់ជាផ្សារក្ដៅ
សោកសៅមិនខាន ។



# ស្ថានីយ៍វិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា
# ដែលសំដែងដោយ ខ្ញុំព្រះករុណា_អាត្មាភាព ចាន់ សុជន

| ខេត្ត_ក្រុង | វេលាផ្សាយ | ស្ថានីយ៍វិទ្យុ |
|---|---|---|
| បន្ទាយមានជ័យ | ៥:៣០ ព្រឹក<br>៨:០០ ល្ងាច ( សៅរ៍_អាទិត្យ )<br>បន្តផ្ទាល់ពីប្រទេស ស្រីលង្កា | FM ៩៩ MHz |
| កំពង់ធំ | ៥:៣០ ព្រឹក | FM ៩៨.៣ MHz |
| ឧត្តរមានជ័យ | ៥:៣០ ព្រឹក | FM ៩០.៥ MHz |

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង




ឥឡូវនេះ អាត្មាអញមានភេទខុសពីគ្រហស្ថហើយ !

## ការទ្រាំចិត្ត

បុថុជ្ជននៅល្ងង់លង់កិលេស ដូច្នេះចូរប្រឹងកុំខឹងពាសវាល
សេពគប់បណ្ឌិតពិតកុំរយាល កុំខ្ជិលដេកទ្រាលកុំអួតខ្លួនឯង ។
មើលចុះភ្នំធំក៏គង់រលាយ ទឹកបឹងទាំងឡាយហួតដោយសូរសែង
ខ្លួនយើងតូចម្លឹងត្រូវប្រឹងកោតក្រែង កុំលើកខ្លួនឯងត្រូវក្រែងបេះគេ ។
ទោះបីទ្រង់គ្រឿងរុងរឿងដោយយស ដើរអួតឫកខ្ពស់យសសូន្យទទេ
ទ្រង់ចិត្តដោយធម៌កាយមិនទំនេរ មកុដសីលលើសិរគេឯងបានសុខ ។